ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀន

## ការអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា
## បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ

នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ
២០២៣

## មាតិកា


បញ្ជីតារាង.....3
បុព្វកថា.....4
១. សេចក្ដីផ្ដើម.....5
១.១ ទិដ្ឋភាពទូទៅ.....5
១.២ មាតិកាសង្ខេប.....5
១.៣ សនិទានភាព.....6
២. ចក្ខុវិស័យ.....6
៣. គោលបំណង.....6
៤. ប្រធានបទសំខាន់ៗសម្រាប់ការអប់រំគ្រូបង្រៀន.....9
៤.១ គោលវិធីសិស្សមជ្ឈមណ្ឌល.....9
៤.២ ការអប់រំបរិយាបន្ន និងពិពិធភាព.....9
៤.៣ ការពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន.....10
៤.៤ ការសិក្សាពេញមួយជីវិត និងបំណិនសតវត្សរ៍ទី២១.....10
៥. ក្រេឌីតសិក្សា.....11
៥.១ ការគណនាក្រេឌីត.....11
៥.២ ការគណនាក្រេឌីតសម្រាប់មុខវិជ្ជាបង្រៀន និងសកម្មភាពដែលត្រូវបានទទួលស្គាល់ដទៃទៀត.....12
៦. ការផ្ដល់ក្រេឌីត និងគុណវុឌ្ឍិ.....14
៦.១ គុណវុឌ្ឍិការអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២.....14
៦.២ គុណវុឌ្ឍិកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤.....15
៧. បណ្ដុំមុខវិជ្ជាសិក្សា.....15
៧.១ ការសិក្សាពីការអប់រំ.....16
៧.២ ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស.....17
៧.៣ ការសិក្សាពីកម្មវិធីសិក្សា.....18
៧.៤ កម្មសិក្សាគរុកោសល្យ.....18
៧.៥ ការស្រាវជ្រាវ.....19
៧.៦ សកម្មភាពក្រៅកម្មវិធីអប់រំ.....19
៨. ប្រភេទមុខវិជ្ជាសិក្សា.....20
៨.១ មុខវិជ្ជាសិក្សាស្នូល.....20
៨.២ មុខវិជ្ជាសិក្សាកាតព្វកិច្ច.....21



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៨.៣ មុខវិជ្ជាសិក្សាជម្រើស ........ 21
៩. ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត ........ 22
៩.១ រចនាសម្ព័ន្ធនៃឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត ........ 22
៩.២ ការប្រើប្រាស់ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតសម្រាប់ការអភិវឌ្ឍកម្មវិធីអប់រំ ........ 24
១០. សនិទានភាពនៃការបន្ស៊ីក្រេឌីតតាមកម្មវិធីអប់រំ ........ 24
១១. ក្របខណ្ឌកម្មវិធីអប់រំក្នុងការបែងចែកក្រេឌីត ........ 25
១១.១ ទិដ្ឋភាពទូទៅនៃការបែងចែកក្រេឌីត ........ 26
១១.២ កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា ........ 28
១១.៣ កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២ ........ 28
១១.៤ កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ ........ 29
១១.៥ កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ ........ 30
១១.៦ កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ ........ 30
១២. យន្តការវាយតម្លៃ ........ 31
១២.១ គោលបំណងនៃការវាយតម្លៃ ........ 31
១២.២ ប្រព័ន្ធពិន្ទុ និងនិទ្ទេស ........ 32
១២.៣ ការវាយតម្លៃមុខវិជ្ជាបង្រៀន ........ 33
១២.៤ ការវាយតម្លៃកម្មសិក្សាគរុកោសល្យ ........ 34
១២.៥ ការវាយតម្លៃសមាសភាគការស្រាវជ្រាវ ........ 36
១៣. បញ្ជីគន្លនិទ្ទេស ........ 38
សទ្ទានុក្រម ........ 40

## បញ្ជីតារាង


តារាងទី 1៖ ការគណនាក្រេឌីតសម្រាប់ការអប់រំគ្រូបង្រៀន ............ 12

តារាងទី 2៖ ការគណនាក្រេឌីតសម្រាប់មុខវិជ្ជាបង្រៀនទូទៅ និងសកម្មភាពដែលត្រូវបានទទួលស្គាល់ ............ 12

តារាងទី 3៖ ការគណនាក្រេឌីតសម្រាប់សមាសភាគកម្មសិក្សាគរុកោសល្យ ............ 13

តារាងទី 4៖ ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការអប់រំ ............ 13

តារាងទី 5៖ ការប្តូរចំនួនក្រេឌីតទៅចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍ ............ 14

តារាងទី 6៖ រចនាសម្ព័ន្ធនៃសមត្ថភាពអប់រំគរុនិស្សិត ១២+២ ............ 23

តារាងទី 7៖ រចនាសម្ព័ន្ធនៃសមត្ថភាពអប់រំគរុនិស្សិត ១២+៤ ............ 23

តារាងទី 8៖ សេចក្តីសង្ខេបពីការផ្តល់ក្រេឌីតនៅគ្រប់កម្មវិធីអប់រំតាមប្រព័ន្ធ ១២+២ និង១២+៤ ............ 26

តារាងទី 9៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២ ............ 28

តារាងទី 10៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២ ............ 29

តារាងទី 11៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ ... 29

តារាងទី 12៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ ............ 30

តារាងទី 13៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ ... 31

តារាងទី 14៖ ប្រព័ន្ធពិន្ទុ និងនិទ្ទេស ............ 32



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# បុព្វកថា

គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់នៅក្នុងការអប់រំនៅកម្ពុជា។ កំណែទម្រង់កម្មវិធីអប់រំគ្រូបង្រៀនគឺជាសកម្មភាពអាទិភាពមួយក្នុងចំណោមសកម្មភាពអាទិភាពផ្សេងទៀតនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីអប់រំគ្រូបង្រៀនបច្ចុប្បន្ន ត្រូវតែបន្តពង្រឹងដោយផ្សារភ្ជាប់ជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ គុណសម្បទាវិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដាសាកល។

គោលបំណងចម្បងនៃក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះ ដើម្បីជានាសុខដុមនីយកម្មប្រព័ន្ធអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀនរួមមាន ការពិនិត្យប្រព័ន្ធក្រេឌីត ការរៀបចំកម្មវិធីអប់រំ វិធីសាស្ត្របង្រៀន ការស្រាវជ្រាវប្រតិបត្តិ និងកម្មសិក្សាគរុកោសល្យស្របតាមក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនថ្នាក់តំបន់ និងសាកល ព្រមទាំងឧត្តមានុវត្តនានា។ ក្របខណ្ឌនេះ ជាឯកសារណែនាំលម្អិតសម្រាប់គាំទ្រគ្រឹះស្ថានអប់រំគ្រូបង្រៀនទាំងអស់ក្នុងការរៀបចំកម្មវិធីអប់រំតាមប្រព័ន្ធក្រេឌីត ដើម្បីពង្រឹងកម្មវិធីអប់រំគ្រូបង្រៀនឱ្យសម្រេចបាននូវចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការផលិតធនធានគ្រូបង្រៀនប្រកបដោយគុណសម្បទាខ្ពស់។

ក្របខណ្ឌនេះផ្តល់មូលដ្ឋានក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដែលមានសញ្ញាបត្រ "១២+២" ទៅកម្រិតបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន និងការប្រែក្លាយសាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទៅជាវិទ្យាស្ថានគរុកោសល្យ។

ក្រសួងសូមថ្លែងអំណរគុណចំពោះមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ ដែលបានគាំទ្រផ្នែកបច្ចេកទេស និងថវិកាក្នុងការអភិវឌ្ឍក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះ។ ក្រសួងជំរុញគ្រឹះស្ថានអប់រំគ្រូបង្រៀន និងអង្គភាពក្រោមឱវាទចូលរួមអនុវត្តក្របខណ្ឌនេះ និងដៃគូអភិវឌ្ឍន៍ចូលរួមគាំទ្រដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអប់រំ។

ថ្ងៃ សុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

## ១. សេចក្តីផ្តើម

### ១.១ ទិដ្ឋភាពទូទៅ

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនជាឯកសារដែលអ្នកពាក់ព័ន្ធនឹងការអភិវឌ្ឍកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិអាចយកទៅប្រើប្រាស់តាមតម្រូវការ។

ឯកសារនេះ ត្រូវបានរៀបចំឡើងដើម្បីគាំទ្រគ្រូឧទ្ទេស និងគ្រឹះស្ថានអប់រំគ្រូបង្រៀនក្នុងការរៀបចំកម្មវិធីអប់រំតាមប្រព័ន្ធក្រេឌីត។

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះបានបញ្ចូលខ្លឹមសារដែលអ្នកអភិវឌ្ឍកម្មវិធីអប់រំអាចយកមកប្រើប្រាស់ក្នុងការអភិវឌ្ឍកម្មវិធីអប់រំលម្អិត និងខ្លឹមសារវគ្គសិក្សាដែលមានការទទួលស្គាល់។ ឯកសារនេះមានគោលការណ៍ណែនាំស្តីពីសមាសភាពការស្រាវជ្រាវនិងកម្មសិក្សាគរុកោសល្យ ប្រភេទសកម្មភាពសិក្សាផ្សេងៗ យន្តការវាយតម្លៃ និងក្របខណ្ឌដាក់ពិន្ទុ។

ដោយអនុលោមតាមផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធានាសុខដុមនីយកម្មរវាងគ្រឹះស្ថានអប់រំគ្រូបង្រៀនទាំងអស់ និងការធានាសង្គតិភាពនិងភាពដែលអាចប្រៀបធៀបគ្នាបានពីកម្មវិធីមួយទៅកម្មវិធីមួយ គោលការណ៍ណែនាំដែលមាននៅក្នុងក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះអាចយកទៅអនុវត្តបានចំពោះគ្រប់កម្មវិធីអប់រំគ្រូបង្រៀន ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀននីមួយៗអាចមានភាពបត់បែនក្នុងការរៀបចំកាលវិភាគ និងលំដាប់លំដោយនៃខ្លឹមសារកម្មវិធី។

### ១.២ មាតិកាសង្ខេប

ឯកសារក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះរួមមាន ***ចក្ខុវិស័យ*** (ផ្នែកទី២) ខ្លឹមសារសង្ខេបស្តីពី ***គោលបំណង*** នៃក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនក្នុងការគាំទ្រការអភិវឌ្ឍកម្មវិធីអប់រំគ្រូបង្រៀន(ផ្នែកទី៣) និងខ្លឹមសារសង្ខេបទូទៅស្តីពី ***គោលនយោបាយអាទិភាពនាពេលបច្ចុប្បន្នរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអប់រំគ្រូបង្រៀន*** (ផ្នែកទី៤) ។

ឯកសារនេះបង្ហាញពី ***ក្រេឌីតសិក្សា***នៃកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ (ផ្នែកទី៥) និង ***ខ្លឹមសារសង្ខេបស្តីពីការផ្តល់ក្រេឌីត និងគុណវុឌ្ឍិ***សម្រាប់ការអប់រំគ្រូបង្រៀន ( ផ្នែកទី៦)។ ការរៀបចំផ្នែកនីមួយៗ គឺផ្អែកលើក្របខណ្ឌគុណវុឌ្ឍិកម្ពុជា ។

ឯកសារនេះ ផ្តល់និយមន័យនៃការបែងចែកប្រភេទខ្លឹមសារកម្មវិធីផ្អែកលើ ***បណ្តុំមុខវិជ្ជាសិក្សា*** ចំនួន៥ (ផ្នែកទី៧) ប្រភេទ ***មុខវិជ្ជាសិក្សា***ចំនួន៣ (ផ្នែកទី៨) និងខ្លឹមសារសង្ខេបស្តីពី ***គុណសម្បទាអប់រំគរុនិស្សិត***ដែលបានបន្សីុជាមួយស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ផ្នែកទី៩)។ ខ្លឹមសារនេះនឹងត្រូវអនុវត្តនៅទូទាំងកម្មវិធីអប់រំគ្រូបង្រៀន ដើម្បីលើកកម្ពស់ការបន្សីុគ្នា និងសង្គតិភាពកម្មវិធីអប់រំគ្រូបង្រៀន។

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធក្រេឌីត ចាប់ផ្តើមដោយ ***ខ្លឹមសារសង្ខេបនៃសនិទានភាពការបន្សីុក្រេឌីតនៅគ្រប់កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់*** (ផ្នែកទី១០) ***ទិដ្ឋភាពទូទៅនៃការបែងចែកក្រេឌីតនៅគ្រប់កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់*** (ផ្នែកទី១១.១) និងក្របខណ្ឌដាច់ដោយឡែកក៏ដូចជាសនិទានភាពក្នុងការបែងចែកក្រេឌីតសម្រាប់៖

- កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២ (ផ្នែកទី១១.២)
- កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២ និង ១២+៤ (ផ្នែកទី១១.៣ & ១១.៥)
- កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ និង ១២+៤ (ផ្នែកទី១១.៤&១១.៦)។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទិដ្ឋភាពទូទៅស្តីពី ***យន្តការវាយតម្លៃផ្អែកលើកម្មវិធី*** រួមទាំងការដាក់ពិន្ទុត្រូវបានបង្ហាញនៅផ្នែកទី១២។ ខ្លឹមសារនេះនឹងត្រូវអនុវត្តនៅទូទាំងកម្មវិធីអប់រំគ្រូបង្រៀន ដើម្បីលើកកម្ពស់ការបន្សុីគ្នា និងសង្គតិភាពកម្មវិធីអប់រំគ្រូបង្រៀន។ បន្ថែមលើនេះ ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនក៏បានបញ្ចូលបញ្ជីគន្ថនិទ្ទេសអំពីឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រជាតិពាក់ព័ន្ធទាំងអស់ដើម្បីឱ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់ជាឯកសារយោង។

### ១.៣ សនិទានភាព

ការអប់រំគ្រូបង្រៀននៅប្រទេសកម្ពុជាបច្ចុប្បន្នបាន និងកំពុងកែទម្រង់ផ្អែកលើអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកែលម្អសាលារៀន។ ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀន គឺជាលទ្ធផលមួយនៃកំណែទម្រង់ ហើយត្រូវបានរៀបចំឡើងក្នុងគោលបំណងរួមចំណែកដល់ការសម្រេចបាននូវផែនការនាពេលបច្ចុប្បន្នរបស់ក្រសួងអប់រំ យុវជន និងកីឡា។ សនិទានភាពនៃការអភិវឌ្ឍក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនមានដូចជា៖

- ឯកសារនេះបានរៀបចំឡើង ក្នុងគោលបំណងអភិវឌ្ឍក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនដែលគ្រប់ដណ្តប់ និងធានាបាននូវសុខដុមនីយកម្មរវាងកម្មវិធីអប់រំគ្រូបង្រៀន និងស្តង់ដានៅគ្រប់គ្រឹះស្ថានអប់រំគ្រូបង្រៀនរួមមានសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានគរុកោសល្យ។ ការធ្វើសុខដុមនីយកម្មនេះ រួមមានប្រព័ន្ធក្រេឌីត ទម្រង់កម្មវិធីអប់រំ និងការអនុវត្ត
- ការដាក់ចេញក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធក្រេឌីត ក្នុងគោលបំណងឱ្យឆ្លើយតបនឹងគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការពិនិត្យ និងការកែលម្អកម្មវិធីនៅគ្រឹះស្ថានអប់រំគ្រូបង្រៀននាពេលអនាគត
- ការអភិវឌ្ឍឯកសារនេះ ជួយឱ្យមានសង្គតិភាពក្នុងការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនតាមរយៈ ១) ការធានាការសម្របសម្រួលថ្នាក់ជាតិ និង ២) ការបង្កើតឱ្យមានប្រព័ន្ធក្រេឌីតដើម្បីគាំទ្រការបន្សុីគ្នារវាងកម្មវិធីអប់រំគ្រូបង្រៀន និង សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

គោលបំណងជារួមនៃឯកសារនេះ ធានាថាគរុនិស្សិតទាំងអស់ (មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ទទួលបានការអប់រំប្រកបដោយគុណភាពសមមូលគ្នា តាមស្តង់ដាជាតិ និងសកល សម្រាប់ឧត្តមភាពវិជ្ជាជីវៈគ្រូបង្រៀន។

រាល់ខ្លឹមសារ និងគោលការណ៍ណែនាំនៅក្នុងឯកសារនេះត្រូវបានអភិវឌ្ឍឡើងដោយអនុលោមតាមគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានស្រាប់សម្រាប់ការអប់រំគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## ២. ចក្ខុវិស័យ

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះមានចក្ខុវិស័យ កសាងធនធានគ្រូបង្រៀនប្រកបដោយគុណសម្បទាពេញលេញឆ្លើយតបទៅនឹងតម្រូវការ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចក្នុងបរិបទកម្ពុជា តំបន់ និងសកលលោក។

## ៣. គោលបំណង

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនមានគោលបំណង៖

- ចង្អុលបង្ហាញអំពីការអភិវឌ្ឍកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធក្រេឌីត

- រៀបចំក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការអប់រំគ្រូបង្រៀនដែលនឹងផលិតគ្រូបង្រៀនប្រកបដោយគុណសម្បទាវិជ្ជាជីវៈ
- លើកកម្ពស់គោលនយោបាយ និងយុទ្ធសាស្ត្រជាតិសម្រាប់ការអប់រំគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- ធានាភាពជាអ្នកដឹកនាំ និងគ្រប់គ្រងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ប្រកបដោយប្រសិទ្ធភាព។

លទ្ធផលរំពឹងទុកនៃកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ និង ១២+៤ ត្រូវបានកំណត់ដោយអនុលោមតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាឆ្នាំ២០១២ ដូចខាងក្រោម៖

- **ចំណេះដឹង**
  - PLO1: កំណត់បានពីតម្រូវការនៃការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សា និងរបៀបរៀនរបស់សិស្ស
  - PLO2: កំណត់បានច្បាស់លាស់អំពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ (ឧទាហរណ៍ យេនឌ័រ ប្រវត្តិសង្គមនិង សេដ្ឋកិច្ច ពិការភាព និងវប្បធម៌ចម្រុះ) ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងវិធីដោះស្រាយបញ្ហាពាក់ព័ន្ធទាំងនោះ
  - PLO3: ពិពណ៌នាពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងនៃការអប់រំចំណេះទូទៅ
  - PLO4: រៀបរាប់ពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយ ក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរ
- **ជំនាញក្នុងការគិត (ចំណេះដឹងវិភាគ)**
  - PLO5: រៀបចំកិច្ចតែងការបង្រៀនប្រកបដោយប្រសិទ្ធភាព ផ្អែកលើបរិបទជាក់ស្តែង
  - PLO6: អភិវឌ្ឍកិច្ចតែងការបង្រៀន កម្មវិធីសិក្សាលម្អិត និងការវាយតម្លៃសមស្រប និងមានប្រសិទ្ធភាព
  - PLO7: ប្រើប្រាស់កម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងបង្រៀនបានត្រឹមត្រូវ
  - PLO8: បញ្ចូលខ្លឹមសារមេរៀនពីប្រធានបទមួយទៅប្រធានបទមួយដែលនាំឱ្យសិស្សទទួលបានបំណិន យកទៅប្រើប្រាស់បាន និងមានឆន្ទៈក្នុងការរៀន
  - PLO9: ប្រើប្រាស់បច្ចេកទេសបង្រៀនសមស្របទៅនឹងរបៀបរៀនរបស់សិស្ស
  - PLO10: ធ្វើការស្រាវជ្រាវប្រតិបត្តិដើម្បីអភិវឌ្ឍវិជ្ជាជីវៈ និងការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព
  - PLO11: វាយតម្លៃគុណផលសិស្សជាប្រព័ន្ធ ដូចនេះសិស្សទទួលបានការគាំទ្រប្រកបដោយប្រសិទ្ធភាពតាមមធ្យោបាយសមស្រប

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- PLO12: វាយតម្លៃនិងឆ្លុះបញ្ចាំងការអនុវត្តការបង្រៀននិងរៀបចំផែនការដើម្បីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- PLO13: ដោះស្រាយបញ្ហាប្រឈមដែលកើតមានក្នុងថ្នាក់រៀនប្រកបដោយការរិះគិត និងច្នៃប្រឌិតដើម្បីធ្វើឱ្យការរៀន និងបង្រៀនប្រសើរឡើង

- **ជំនាញទំនាក់ទំនង បច្ចេកវិទ្យា និងលេខនព្វន្ត**
  - PLO14: ប្រើប្រាស់ព័ត៌មាន បច្ចេកវិទ្យា និងទំនាក់ទំនង ដើម្បីលើកកម្ពស់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព កសាង ប្រមូល វិភាគ និងរក្សាទុកដំណើរការនិងការផ្ទេរទិន្នន័យប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ
  - PLO15: ប្រើប្រាស់ចំណេះដឹង និងបំណិនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងឌីជីថលដើម្បីគាំទ្រការបង្រៀននិងរៀន
- **ជំនាញទំនាក់ទំនងអន្តរបុគ្គល និងទំនួលខុសត្រូវ**
  - PLO16: ផ្តល់ព័ត៌មានគ្រប់ជូនដល់សិស្ស មាតាបិតា ឬអ្នកអាណាព្យាបាល អំពីវឌ្ឍនភាពសិក្សា និងឥរិយាបថរបស់សិស្ស
  - PLO17: បណ្តុះស្មារតីសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ពួកគេ
  - PLO18: ផ្តល់ការយកចិត្តទុកដាក់ចំពោះសិស្ស និង ឬធ្វើការដើម្បីផលប្រយោជន៍សិស្ស និងសង្គម PLO19: បង្ហាញពីការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវខ្ពស់ចំពោះវិជ្ជាជីវៈគ្រូបង្រៀន
  - PLO20: អភិវឌ្ឍការគិតជាវិជ្ជមាន ជាបុគ្គលគំរូ និងមានអាកប្បកិរិយាជាពលរដ្ឋសកល ជាមួយសិស្ស និងសហគមន៍ប្រកបដោយវិជ្ជាជីវៈនិងសុខដុមនីយកម្ម
  - PLO21: បង្កើតទំនាក់ទំនងល្អជាមួយសិស្ស អ្នកអាណាព្យាបាល សហសេវិក និងសហគមន៍ PLO22: ចូលរួមអភិវឌ្ឍសាលារៀនដើម្បីទ្រទ្រង់ការអប់រំ និងសុខុមាលភាពសិស្សព្រមទាំងសហសេវិក
  - PLO23: សហការជាមួយគ្រូបង្រៀនដទៃទៀតដើម្បីគាំទ្រសកម្មភាពបង្រៀន និងរៀន
- **ជំនាញចិត្តចលនា**
  - PLO24: ផលិតសម្ភារឧបទេសដើម្បីបង្កើនលទ្ធផលសិក្សារំពឹងទុករបស់សិស្ស
  - PLO25: ផ្តល់នូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងអំណោយផល ដែលអាចឱ្យសិស្សបញ្ចេញនូវសក្តានុពលរៀនសូត្រឱ្យអស់ពីសមត្ថភាព
  - PLO26: អនុវត្តសកម្មភាពរៀនសមស្របដើម្បីជួយសម្រួលដល់របៀបរៀន និងតម្រូវការសិក្សារបស់សិស្សតាមរយៈវិធីសាស្ត្រចម្រុះ និងបត់បែន
  - PLO27: ផ្តល់ឱកាសដល់សិស្សចូលរួមដោះស្រាយបញ្ហាដោយប្រើកម្លាំងកាយ និងបញ្ញាស្មារតីតាមរយៈការគិតបែបស៊ីជម្រៅនិងច្នៃប្រឌិត
  - PLO28: អនុវត្តការវាយតម្លៃជាក់ស្តែងដែលតម្រូវឱ្យសិស្សធ្វើកិច្ចការដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងស្ថានភាពរស់នៅប្រចាំថ្ងៃ។

កម្រិតខុសគ្នានៃលទ្ធផលសិក្សារំពឹងទុករបស់កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ១២+២ និង១២+៤ នឹងត្រូវបានកំណត់ ច្បាស់លាស់ក្នុងឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត។

### ៤. ប្រធានបទសំខាន់ៗសម្រាប់ការអប់រំគ្រូបង្រៀន

ផែនការក្នុងការអប់រំគ្រូបង្រៀន និងក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះ គឺស្ថិតក្នុងបរិបទទូលំទូលាយដែលជាអាទិភាពជាតិសម្រាប់វិស័យអប់រំនាពេលបច្ចុប្បន្ន។ កម្មវិធីអប់រំគ្រូបង្រៀនក្នុងប្រទេសកម្ពុជាចាំបាច់ត្រូវបន្សុីគ្នាជាមួយគោលនយោបាយអាទិភាពសំខាន់ៗដើម្បីធានាថាអាទិភាពទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការអប់រំគ្រូបង្រៀន។ អាទិភាពសំខាន់ៗរួមមាន៖

- គោលវិធីសិស្សមជ្ឈមណ្ឌល
- ការអប់រំបរិយាបន្ន និងពិពិធភាព
- ការពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន
- ការសិក្សាពេញមួយជីវិត និងបំណិនសតវត្សរ៍ទី២១

ក្នុងការរៀបចំកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវបញ្ចូល គោលនយោបាយអាទិភាពទាំងអស់នេះនៅគ្រប់មុខវិជ្ជាសិក្សា ខ្លឹមសារមេរៀន កិច្ចការវាយតម្លៃ និងលទ្ធផលដែលមានការទទួលស្គាល់។

#### ៤.១ គោលវិធីសិស្សមជ្ឈមណ្ឌល

គោលនយោបាយរាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន គាំទ្រគ្រប់ការបង្រៀន និងរៀនតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល។

ក្នុងន័យគរុកោសល្យ គោលវិធីសិស្សមជ្ឈមណ្ឌលផ្តល់ឱ្យអ្នកសិក្សានូវតួនាទីផ្ទាល់ និងសកម្មក្នុងដំណើរការនៃការសិក្សា។ គោលវិធីសិស្សមជ្ឈមណ្ឌលទាមទារឱ្យគ្រូបង្រៀនតាក់តែង និងផ្តល់ការបង្រៀនធ្វើយ៉ាងណាឱ្យអ្នកសិក្សាចូលរួមយ៉ាងសកម្មនៅក្នុងការស្វែងរក និងប្រើប្រាស់ចំណេះដឹងថ្មីៗ ដើម្បីស្ថាបនាចំណេះដឹងរបស់ខ្លួនលើមុខវិជ្ជា ព្រមទាំងអភិវឌ្ឍបំណិនដើម្បីយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។

គ្រូបង្រៀនអាចសម្រេចបានគោលបំណងនេះតាមរយៈ (១) ការប្រើប្រាស់បច្ចេកទេសគ្រប់គ្រងថ្នាក់រៀនដែលជំរុញឱ្យសិស្សមានការចូលរួមសកម្ម (២) ការរៀបចំសកម្មភាពសិក្សាដែលជំរុញឱ្យសិស្សចូលរួមក្នុងការស្រាវជ្រាវនិងការស្វែងរក និង (៣) ការរៀបចំកិច្ចតែងបង្រៀនដែលជំរុញឱ្យសិស្សប្រើប្រាស់ចំណេះដឹងមានស្រាប់។

កម្មវិធីអប់រំគ្រូបង្រៀន មានតួនាទីណែនាំឱ្យគរុនិស្សិត ស្គាល់អំពីគោលការណ៍ និងទ្រឹស្តីការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល ព្រមទាំងធ្វើឱ្យគរុនិស្សិតទទួលបានបច្ចេកទេសជាច្រើនដែលពួកគេអាចយកទៅអនុវត្តជាក់ស្តែងបាន។ ដូច្នេះកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវបញ្ចូលគោលវិធីសិស្សមជ្ឈមណ្ឌលនៅក្នុងការបង្រៀនរបស់ខ្លួន ព្រមទាំងរំលេចការធ្វើបទបង្ហាញ ការពិភាក្សា និងការឆ្លុះបញ្ចាំងលើគោលវិធីសិស្សមជ្ឈមណ្ឌលដែលជាទិដ្ឋភាពដ៏សំខាន់នៃមុខវិជ្ជាសិក្សា និងសកម្មភាពដែលមានការទទួលស្គាល់។

#### ៤.២ ការអប់រំបរិយាបន្ន និងពិពិធភាព

ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ការអប់រំប្រកបដោយបរិយាបន្ន និងសមធម៌សម្រាប់ទាំងអស់គ្នា ជាវត្ថុបំណងមួយក្នុងចំណោមវត្ថុបំណងធំពីរនៃគោលនយោបាយសម្រាប់វិស័យអប់រំទាំងមូល។ ដើម្បីសម្រេចវត្ថុបំណងនេះ ប្រព័ន្ធអប់រំទាំងមូលត្រូវធានាឱ្យបានថាសិស្សទាំងអស់មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព មិនប្រកាន់ភេទ ជនជាតិដើមភាគតិច ស្ថានភាពសង្គមឬសេដ្ឋកិច្ច ឬសមត្ថភាពកាយសម្បទាឬផ្លូវចិត្ត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីដោះស្រាយបញ្ហានេះនៅកម្រិតថ្នាក់រៀន វាពិតជាមានសារៈសំខាន់ណាស់ក្នុងការធានាឱ្យបានថា គ្រូបង្រៀនបានដឹងអំពីឧបសគ្គនានាដែលរាំងការសិក្សារបស់សិស្សម្នាក់ៗ ហើយអាចបង្ហាញវិធីសាស្ត្រជាច្រើនដែលពួកគេអាចយកមកប្រើប្រាស់ក្នុងការគាំទ្រសិស្សនៅក្នុងថ្នាក់រៀន។

កម្មវិធីអប់រំគ្រូបង្រៀនមានតួនាទីផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងការយល់ដឹងពីបញ្ហាប្រឈមដែលសិស្សងាយរងគ្រោះកំពុងជួបប្រទះ ព្រមទាំងផ្តល់បច្ចេកទេសជាច្រើនឱ្យពួកគេដើម្បីជួយសិស្សជម្នះបញ្ហាប្រឈមទាំងនោះ។ ដូច្នេះកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់គួរតែបង្ហាញនូវវិធីសាស្ត្រចម្រុះនៅក្នុងការជ្រើសរើស និងការបង្រៀនព្រមទាំងរំលេចក្នុងការធ្វើបទបង្ហាញ ការពិភាក្សា និងការឆ្លុះបញ្ចាំងអំពីកម្មវិធីអប់រំបរិយាបន្នដែលជាទិដ្ឋភាពគន្លឹះមួយសម្រាប់គ្រប់មុខវិជ្ជាសិក្សា និងសកម្មភាពដែលមានការទទួលស្គាល់។

## ៤.៣ ការពង្រឹងវិជ្ជាជីវៈគ្រូបង្រៀន

គោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនរបស់រាជរដ្ឋាភិបាលបច្ចុប្បន្នសំដៅពង្រឹងវិជ្ជាជីវៈសម្រាប់ការងារគ្រូបង្រៀនទាំងមូល។ ឧទាហរណ៍ពាក់ព័ន្ធមួយចំនួនរួមមានវត្ថុបំណងគោលនយោបាយសម្រាប់ (១) ការពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងវិស័យអប់រំគ្រប់កម្រិត (២) ការលើកកម្ពស់យន្តការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងការអភិវឌ្ឍអាជីពរយៈពេលវែង និង (៣) ការឆ្លើយតបចំពោះគុណភាពទូទៅ និងការផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាល និងវិក្រឹតការ។

តាមរយៈវិធានការទាំងនេះ គេរំពឹងថាប្រព័ន្ធអប់រំនឹងអាចទាក់ទាញ និងរក្សាទុកបេក្ខជនមានសមត្ថភាពព្រមទាំងលើកទឹកចិត្តពួកគេឱ្យកាន់តែមានបំណិន មានទឹកចិត្ត និងមានការប្តេជ្ញាចិត្តកាន់តែខ្ពស់ដែលនឹងនាំឱ្យការអនុវត្តការងារ និងលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ។

ដើម្បីគាំទ្រដំណើរការនេះ គ្រឹះស្ថានអប់រំគ្រូបង្រៀនទាំងអស់គួរធានាឱ្យបានថា៖

- **នៅកម្រិតគ្រឹះស្ថាន៖** កម្មវិធីអប់រំគ្រូបង្រៀនមានភាពបន្សុីគ្នាជាមួយយន្តការថ្នាក់ជាតិដែលមានការប្រែប្រួលជាប្រចាំសម្រាប់ការបន្សុីក្រេឌីត ការផ្ទេរការសិក្សារបស់គរុនិស្សិត និងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានអប់រំគ្រូបង្រៀន
- **នៅកម្រិតកម្មវិធីអប់រំ៖** កម្មវិធីអប់រំគ្រូបង្រៀនត្រូវធានាឱ្យបានថា គរុនិស្សិតទទួលបានបំណិនវិជ្ជាជីវៈ និងចំណេះដឹងជាក់លាក់ដើម្បីឱ្យគរុនិស្សិត (១) ទទួលបានគុណសម្បទាវិជ្ជាជីវៈ គ្រូបង្រៀនដែលបានកំណត់នៅពេលបញ្ចប់ការអប់រំ និង (២) មានសមត្ថភាពបន្តការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈយន្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំថ្នាក់ជាតិ
- **នៅកម្រិតការបង្រៀន៖** កម្មវិធីអប់រំគ្រូបង្រៀនផ្តល់ឱ្យគរុនិស្សិតនូវឱកាសអនុវត្តនូវចំណេះដឹងទ្រឹស្តី នៅតាមសាលារៀន ផ្តល់បទពិសោធន៍ និងការយល់ដឹងពាក់ព័ន្ធដើម្បីអភិវឌ្ឍគុណសម្បទាគុណតម្លៃ និងចរិយាសម្បទាវិជ្ជាជីវៈគ្រូបង្រៀន។

ដើម្បីសម្រេចបានតាមលក្ខខណ្ឌតម្រូវខាងលើ គ្រឹះស្ថានអប់រំគ្រូបង្រៀនទាំងអស់ត្រូវធានាថាកម្មវិធីអប់រំរួមចំណែកក្នុង (១) ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន (២) ការលើកទឹកចិត្តនិងការចូលរួមពីគ្រូបង្រៀន និង (៣) ការផ្តល់នូវការសិក្សាប្រកបដោយគុណភាព។

## ៤.៤ ការសិក្សាពេញមួយជីវិត និងបំណិនសតវត្សរ៍ទី២១

ដើម្បីដោះស្រាយបញ្ហា គុណភាពនៃការអប់រំ ក្រសួងអប់រំយុវជន និងកីឡា បានអភិវឌ្ឍវប្បធម៌សិក្សាពេញមួយជីវិត ទាំងនៅក្នុងការអប់រំគ្រូបង្រៀន និងនៅក្នុងចំណោមប្រជាជនទូទៅ។ ក្រសួងអប់រំ យុវជន និង

កីឡាតម្រូវឱ្យគ្រូបង្រៀន នាយកសាលា និងបុគ្គលិកអប់រំដទៃទៀតក្លាយជាអ្នកសិក្សាពេញមួយជីវិតនៅក្នុងការប្រតិបត្តិវិជ្ជាជីវៈតាមរយៈការសិក្សាដោយការអនុវត្ត ការសាកល្បងវិធីសាស្ត្របង្រៀននិងរៀនថ្មីៗ ការវាយតម្លៃផលជះទៅលើការសិក្សារបស់សិស្ស និងការចូលរួមជាមួយដៃគូនិងសហការីនៅកម្រិតសាលារៀន ដោយប្រើប្រព័ន្ធប្រឹក្សាគរុកោសល្យវិជ្ជាជីវៈប្រកបដោយការគាំទ្រ។

ផែនការដើម្បីអភិវឌ្ឍវប្បធម៌ការសិក្សាពេញមួយជីវិត ក៏ត្រូវបានបន្សីជាមួយគោលបំណងជាតិក្នុងការអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ ទាំងនៅក្នុងវិជ្ជាជីវៈបង្រៀន និងក្នុងចំណោមប្រជាជនទូទៅ។ ដើម្បីឱ្យមានការសិក្សាពេញមួយជីវិតនៅក្នុងបរិបទសកលថ្មីៗ ការអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ត្រូវរួមបញ្ចូលនូវគុណលក្ខណៈជាច្រើនរួមមាន ការច្នៃប្រឌិត ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការប្រាស្រ័យទាក់ទង ការសហការ អក្ខរកម្មឌីជីថល និងបំណិនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ អក្ខរកម្មព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ និងបំណិនសង្គមនិងវប្បធម៌។

កម្មវិធីអប់រំគ្រូបង្រៀន មានតួនាទីណែនាំគរុនិស្សិតពីគោលការណ៍និងការប្រតិបត្តិការសិក្សាពេញមួយជីវិត និងផ្តល់ឱ្យពួកគេនូវឧបករណ៍ផ្សេងៗដែលពួកគេអាចយកទៅប្រើប្រាស់ក្នុងការប្រតិបត្តិវិជ្ជាជីវៈ និងការសិក្សា។

កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវបញ្ចូលសកម្មភាពស្វ័យឆ្លុះបញ្ចាំង ការវិភាគ និងការអភិវឌ្ឍវិជ្ជាជីវៈជាផ្នែកមួយនៃកម្មវិធីស្នូលដូចជា ១) មុខវិជ្ជាបង្រៀន ត្រូវបញ្ចូលសកម្មភាព និងវិធីសាស្ត្របង្រៀនដែលជួយជំរុញដល់ការសិក្សារបស់សិស្ស ២) សមាសភាគការស្រាវជ្រាវ ត្រូវជំរុញឱ្យមានការចូលរួមពីគរុនិស្សិតតាមរយៈការរៀនតាមបែបរិះរក ដើម្បីអភិវឌ្ឍចំណេះដឹងវិជ្ជាជីវៈ និងការប្រតិបត្តិវិជ្ជាជីវៈរបស់ពួកគេ ៣) សមាសភាគកម្មសិក្សាគរុកោសល្យត្រូវជំរុញឱ្យមានការចូលរួមពីគរុនិស្សិត ក្នុងសកម្មភាពស្វ័យឆ្លុះបញ្ចាំងប្រកបដោយការត្រិះរិះ ទៅលើការអនុវត្តការបង្រៀនជាក់ស្តែង ការដោះស្រាយបញ្ហាដោយភាពម្ចាស់ការ និងយន្តការសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍បែបសហការ និង ៤) គ្រប់មុខវិជ្ជាសិក្សាទាំងអស់ត្រូវផ្តល់ឱកាសក្នុងការវាយតម្លៃចំពោះការងារបែបច្នៃប្រឌិតនិងសហការ ទំនាក់ទំនងរវាងមិត្តរួមក្រុម និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងប្រព័ន្ធផ្សព្វផ្សាយឌីជីថលដើម្បីទទួល និងស្វែងរកប្រភពព័ត៌មានថ្មីៗ។

## ៥. ក្រេឌីតសិក្សា

### ៥.១ ការគណនាក្រេឌីត

គំរូនៃការគណនាម៉ោងក្រេឌីតសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នឹងស្របតាមលក្ខខណ្ឌនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងប្រព័ន្ធផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

គំរូនៃការគណនាម៉ោងក្រេឌីតសម្រាប់ការអប់រំគ្រូបង្រៀននឹងប្រើប្រាស់រូបមន្តដូចខាងក្រោម៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*តារាងទី 1៖ ការគណនាក្រេឌីតសម្រាប់ការអប់រំគ្រូបង្រៀន*

| **ស្តង់ដាការគណនា** | **១ ក្រេឌីត =** | **៤៥ ម៉ោងសិក្សាក្នុងមួយឆមាស ១៥ សប្តាហ៍សិក្សា** | |
|---|---|---|---|
| ការបែងចែក | ប្រភេទមុខវិជ្ជាសិក្សា៖ | ម៉ោងសិក្សាក្នុងថ្នាក់/ជួបផ្ទាល់ | ម៉ោងស្វ័យសិក្សា |
| | - បទឧទ្ទេស | ១៥ | ៣០ |
| | - ការបង្រៀនទ្រឹស្តី និងការអនុវត្តក្នុងថ្នាក់ | ៣០ | ១៥ |
| | - ការអនុវត្តក្នុងថ្នាក់/រោងជាង/ពិសោធន៍ | ៣០ | ១៥ |
| | - កម្មសិក្សាគរុកោសល្យ/ ការស្រាវជ្រាវប្រតិបត្តិ/ទស្សនកិច្ចសិក្សា | ៤៥ | |

ការគណនាក្រេឌីត គឺផ្អែកលើចំនួនម៉ោងសរុបនៃការចូលរួមផ្ទាល់ក្នុងថ្នាក់ ឬការអនុវត្តក្នុងថ្នាក់ និងម៉ោងដែលតម្រូវឱ្យគរុនិស្សិតធ្វើស្វ័យសិក្សាបន្ថែមទៀតជុំវិញប្រធានបទ ឬកិច្ចការដែលត្រូវសិក្សា។

### ៥.២ ការគណនាក្រេឌីតសម្រាប់មុខវិជ្ជាបង្រៀន និងសកម្មភាពដែលត្រូវបានទទួលស្គាល់ដទៃទៀត

មុខវិជ្ជាបង្រៀនទូទៅ និងសកម្មភាពដែលត្រូវបានទទួលស្គាល់ គឺអាចមានតម្លៃក្រេឌីតសរុបចំនួន ១ ២ ឬ៣ក្រេឌីត។ មុខវិជ្ជាសិក្សាទូទៅ និងសកម្មភាពទាំងនេះរួមមានមុខវិជ្ជាសិក្សា និងសកម្មភាពដែលត្រូវបានទទួលស្គាល់សម្រាប់បណ្តុំមុខវិជ្ជាសិក្សាភាគច្រើនរួមមាន ការសិក្សាពីការអប់រំ ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស ការសិក្សាពីកម្មវិធីសិក្សា កម្មសិក្សាគរុកោសល្យ និងការស្រាវជ្រាវ។ សម្រាប់មុខវិជ្ជាសិក្សាទូទៅ និងសកម្មភាពដែលត្រូវបានទទួលស្គាល់ទាំងនេះ គរុនិស្សិតត្រូវសិក្សាសរុបចាប់ពីចំនួន ៤៥ ទៅ ១៣៥ ម៉ោងក្នុងមួយឆមាស។

ផ្អែកលើប្រភេទមុខវិជ្ជាសិក្សានីមួយៗដែលបានកំណត់ ម៉ោងសិក្សាទាំងអស់ត្រូវគណនាដូចខាងក្រោម៖

*តារាងទី 2៖ ការគណនាក្រេឌីតសម្រាប់មុខវិជ្ជាបង្រៀនទូទៅ និងសកម្មភាពដែលត្រូវបានទទួលស្គាល់*

| **ការគណនា** | | **១ ក្រេឌីត= ៤៥ ម៉ោងទំហំការងារ** | | **២ ក្រេឌីត= ៩០ ម៉ោងទំហំការងារ** | | **៣ ក្រេឌីត= ១៣៥ ម៉ោងទំហំការងារ** | |
|---|---|---|---|---|---|---|---|
| **ការបែងចែក** | *ប្រភេទមុខវិជ្ជាសិក្សា* | *ម៉ោងសិក្សាក្នុងថ្នាក់/ជួបផ្ទាល់* | *ម៉ោងស្វ័យសិក្សា* | *ម៉ោងសិក្សាក្នុងថ្នាក់/ជួបផ្ទាល់* | *ម៉ោងស្វ័យសិក្សា* | *ម៉ោងសិក្សាក្នុងថ្នាក់/ជួបផ្ទាល់* | *ម៉ោងស្វ័យសិក្សា* |
| | បទឧទ្ទេស | ១៥ | ៣០ | ៣០ | ៦០ | ៤៥ | ៩០ |
| | ការបង្រៀនទ្រឹស្តី និងការអនុវត្តក្នុងថ្នាក់ | ៣០ | ១៥ | ៦០ | ៣០ | ៩០ | ៤៥ |
| | រោងជាង/ ពិសោធន៍ | ៣០ | ១៥ | ៦០ | ៣០ | ៩០ | ៤៥ |

គ្រប់ករណីទាំងអស់ ម៉ោងស្វ័យសិក្សាសរុប គឺត្រូវរួមបញ្ចូលពេលវេលាដែលបានចំណាយលើកិច្ចការ។

វគ្គសិក្សានីមួយៗ អាចរួមបញ្ចូលគ្នារវាងបទឧទ្ទេស រោងជាង និងសកម្មភាពប្រតិបត្តិដែលជាធាតុសម្រាប់តម្លៃក្រេឌីតសរុបអាស្រ័យទៅតាមការតាក់តែងវគ្គសិក្សានីមួយៗនៅតាមកម្រិតកម្មវិធីអប់រំ។ ក្នុងករណីទាំងនេះ ការគណនាក្រេឌីត គឺត្រូវប្រើប្រាស់រូបមន្តម៉ោងក្រេឌីត និងផ្តល់ក្រេឌីតសរុបដែលត្រូវផ្តល់ផ្អែកលើកត្តាផ្សេងៗជាច្រើនដូចជា ចំនួនម៉ោងជួបផ្ទាល់ឬម៉ោងបង្រៀន រយៈពេលនៃវគ្គសិក្សា កម្រិតស្វ័យសិក្សាតាមការរំពឹងទុក និងកិច្ចការ។ ការបែងចែកម៉ោងសម្រាប់ប្រភេទសកម្មភាពនីមួយៗ និងការផ្តល់តម្លៃក្រេឌីតគឺត្រូវគណនាផ្អែកលើតម្លៃម៉ោងមួយក្រេឌីតដូចមានបញ្ជាក់ក្នុងតារាងខាងលើ។

សមាសភាគកម្មសិក្សាគរុកោសល្យ ពុំប្រើប្រាស់គំរូក្រេឌីត ១-៣ ទេ ប៉ុន្តែតម្លៃក្រេឌីតសរុបនៃសមាសភាគកម្មសិក្សាគរុកោសល្យគឺមានតម្លៃចន្លោះពី ២-១០ក្រេឌីតក្នុងមួយឆមាស។ ដូច្នេះសម្រាប់កម្មសិក្សាគរុកោសល្យ គរុនិស្សិតចាំបាច់ត្រូវសិក្សាចន្លោះពី ៩០ ដល់ ៤៥០ម៉ោងសិក្សាក្នុងមួយឆ្នាំ។ ទំហំការងារទាំងនេះរួមមានម៉ោងទាំងអស់សម្រាប់៖

- ការសង្កេតថ្នាក់រៀន
- ការរៀបចំកិច្ចតែងការបង្រៀន
- ការបង្រៀនក្នុងថ្នាក់
- ការប្រជុំជាមួយមិត្តរួមក្រុម គ្រូណែនាំ និងគ្រូដឹកនាំ
- ការស្រាវជ្រាវនៅសាលារៀន និងសកម្មភាពស្វ័យសិក្សា
- ការបញ្ចប់កិច្ចការ
- ការរក្សាផលបត្រកម្មសិក្សាគរុកោសល្យ

ទំហំការងារសម្រាប់សមាសភាគកម្មសិក្សាគរុកោសល្យ គឺត្រូវគណនាដូចខាងក្រោម៖

*តារាងទី 3៖ ការគណនាក្រេឌីតសម្រាប់សមាសភាគកម្មសិក្សាគរុកោសល្យ*

| ការគណនា | ១ ក្រេឌីត |
|---|---|
| កម្មសិក្សាគរុកោសល្យ | ៤៥ ម៉ោងនៃទំហំការងារ |

*តារាងទី 4៖ ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការអប់រំ*

| | (លេខកូដមុខវិជ្ជា) | ឈ្មោះមុខវិជ្ជា | ចំនួនក្រេឌីត (X-Y-Z) |
|---|---|---|---|
| ឧទាហរណ៍ | 101203 | ចិត្តវិទ្យាអប់រំ | ៣ (៣-០-៦) |
| | 101405 | ទស្សនវិជ្ជាអប់រំ | ២ (២-០-៤) |
| ចំនួនក្រេឌីត | ចំនួន១ ២ ឬ៣ក្រេឌីត<br>X ចំនួនម៉ោងសិក្សាទ្រឹស្តី<br>Y ចំនួនម៉ោងសិក្សាប្រតិបត្តិ ឬចំនួនម៉ោងកម្មសិក្សា(សម្រាប់មុខវិជ្ជាកម្មសិក្សា)<br>Z ស្វ័យសិក្សា | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*តារាងទី ៥៖ ការប្តូរចំនួនក្រេឌីតទៅចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍*

| **ការប្តូរក្រេឌីតទៅជាចំនួនម៉ោងសិក្សា** | | |
|---|---|---|
| | ចំនួនក្រេឌីត | ចំនួនម៉ោង |
| ការសិក្សាទ្រឹស្តី | ១ ក្រេឌីត | ១ម៉ោង/សប្តាហ៍ |
| ការសិក្សាប្រតិបត្តិ ឬកម្មសិក្សា | ១ ក្រេឌីត | ២ម៉ោង/សប្តាហ៍ |
| **ការប្តូរចំនួនម៉ោងការសិក្សាទៅជាចំនួនម៉ោងស្វ័យសិក្សា** | | |
| | ចំនួនម៉ោង | ចំនួនម៉ោងស្វ័យសិក្សា |
| ការសិក្សាទ្រឹស្តី | ១ម៉ោង/សប្តាហ៍ | ២ម៉ោង/សប្តាហ៍ |
| ការសិក្សាប្រតិបត្តិ ឬកម្មសិក្សា | ១ម៉ោង/សប្តាហ៍ | កន្លះម៉ោង/សប្តាហ៍ |

ឧទាហរណ៍ទី១៖ មុខវិជ្ជា A ផ្តោតលើការសិក្សាទ្រឹស្តីតែម៉្យាងគត់ចំនួន៣ក្រេឌីត ត្រូវសរសេរ ៣ (៣-០-៦)។

ឧទាហរណ៍ទី២៖ មុខវិជ្ជា B ចំនួន៣ក្រេឌីត សិក្សាទ្រឹស្តីចំនួន២ក្រេឌីត និងការសិក្សាប្រតិបត្តិចំនួន ១ក្រេឌីត ត្រូវសរសេរ ៣ (២-២-៥)។

ឧទាហរណ៍ទី៣៖ មុខវិជ្ជា C ផ្តោតលើការសិក្សាប្រតិបត្តិតែម៉្យាងគត់ចំនួន៣ក្រេឌីត ត្រូវសរសេរ ៣ (០-៦-៣)។

ឧទាហរណ៍ទី៤៖ មុខវិជ្ជា D ចំនួន១ក្រេឌីត ជាកម្មសិក្សាគរុកោសល្យ ត្រូវសរសេរ ១ (០-២-១) ឬ៤៥ ម៉ោង។

## ៦. ការផ្តល់ក្រេឌីត និងគុណវុឌ្ឍិ

កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់នឹងផ្តល់ជូននូវក្រេឌីត និងគុណវុឌ្ឍិស្របតាមលក្ខខណ្ឌនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ប្រព័ន្ធផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងសៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ ការផ្តល់ក្រេឌីត និងគុណវុឌ្ឍិមានដូចខាងក្រោម[1]៖

### ៦.១ គុណវុឌ្ឍិការអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២

កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ ផ្តល់នូវគុណវុឌ្ឍិការអប់រំផ្អែកលើការសិក្សា ២ឆ្នាំនៅកម្រិតឧត្តមសិក្សាដែលមានចំនួនយ៉ាងតិច ៦០ក្រេឌីត ស្មើនឹងបរិញ្ញាបត្ររង (សូមមើលប្លង់កម្មវិធីនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាឆ្នាំ២០១២)។ កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ ផ្តល់ជម្រើសសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាបានកំណត់ដូចខាងក្រោម៖

*"ការផ្តល់សញ្ញាបត្របរិញ្ញាបត្ររង នេះត្រូវបំពេញចំនួនយ៉ាងតិច ៦០ក្រេឌីត បន្ទាប់ពីការសិក្សាពេញម៉ោង រយៈពេលពីឆ្នាំ ឬសមមូលក្នុងការអប់រំឧត្តមសិក្សា...គុណវុឌ្ឍិបរិញ្ញាបត្ររងអាចជាច្រកសម្រាប់ស្វែងរកការងារ ជាពិសេសគឺនៅក្នុងចំណោមការងារជំនាញវិជ្ជាជីវៈ ឬការងារអាជីពនានា និងជាការណែនាំឆ្ពោះទៅរកមូលដ្ឋានគ្រឹះនៃមុខវិជ្ជាមួយ ឬឆ្លងកាត់មុខវិជ្ជាច្រើន"។*

(RGC 2012: 33)

[1] ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនបង្ហាញជម្រើសសម្រាប់ការអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ និង ១២+៤ ប៉ុណ្ណោះ។

សញ្ញាបត្របរិញ្ញាបត្រវេងអប់រំវិជ្ជាជីវៈគ្រូបង្រៀន ត្រូវបានរៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាសម្រាប់ការចូលបម្រើការងារក្នុងវិស័យណាមួយ ព្រមទាំងផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាបន្ថែមទៅដល់ថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន ហើយត្រូវបានបន្សុីគ្នាជាមួយកម្មវិធីបរិញ្ញាបត្រដែលពាក់ព័ន្ធផ្សេងទៀត។

## ៦.២ គុណវុឌ្ឍិកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤

កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ ផ្តល់នូវគុណវុឌ្ឍិមុនពេលបម្រើការងារដោយផ្អែកលើការសិក្សារយៈពេល ៤ឆ្នាំនៃការសិក្សាកម្រិតឧត្តមសិក្សា ដែលមានចំនួនយ៉ាងតិច ១២០ក្រេឌីត និងទទួលបានបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន។ កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ ផ្តល់ជម្រើសសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតែប៉ុណ្ណោះ។

ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាបានកំណត់ដូចខាងក្រោម៖

*"ការផ្តល់សញ្ញាបត្របរិញ្ញាបត្រត្រូវបំពេញចំនួនយ៉ាងតិច ១២០ក្រេឌីតក្នុងរយៈពេល៤ឆ្នាំនៃការសិក្សាពេញម៉ោង ឬសមមូល...ត្រូវបានរៀបចំដើម្បីអភិវឌ្ឍការយល់ដឹងលើការសិក្សាឱ្យបានទូលំទូលាយ ដោយផ្តោតលើការគិតពិចារណា និងវិភាគបែបស៊ីជម្រៅពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងការស្រាវជ្រាវចុងក្រោយ"។*

(RGC 2012: 36)

ការផ្តល់សញ្ញាបត្របរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនធ្វើឡើងក្នុងគោលបំណង អភិវឌ្ឍទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលត្រូវការសម្រាប់អនុវត្តក្នុងវិស័យវិជ្ជាជីវៈជាក់លាក់មួយ។ កម្រិតសញ្ញាបត្របរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនក៏ផ្តល់នូវសារៈតារចំណេះដឹងអនុវត្តនិងទ្រឹស្តី រួមទាំងការស្រាវជ្រាវដែលអាចឱ្យអ្នកបញ្ចប់ការសិក្សា បន្តការសិក្សានៅថ្នាក់ក្រោយបរិញ្ញាបត្រ។

## ៧. បណ្តុំមុខវិជ្ជាសិក្សា

កម្មវិធីអប់រំគ្រូបង្រៀននឹងផ្តល់នូវប្រធានបទសិក្សា និងសកម្មភាពជាច្រើនដែលបែងចែកជា ៥បណ្តុំមុខវិជ្ជាសិក្សា៖

- ការសិក្សាពីការអប់រំ
- ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស
- ការសិក្សាពីកម្មវិធីសិក្សា
- កម្មសិក្សាគរុកោសល្យ
- ការស្រាវជ្រាវ

មុខវិជ្ជាសិក្សា ឬសកម្មភាពដែលត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងការអប់រំគ្រូបង្រៀនស្ថិតក្នុងចំណោមបណ្តុំមុខវិជ្ជាសិក្សាទាំង៥។

កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់នៅក្នុងប្រព័ន្ធអប់រំគ្រូបង្រៀននៅកម្ពុជានឹងប្រើប្រាស់បណ្តុំមុខវិជ្ជាសិក្សាទាំង៥ សម្រាប់ការបែងចែកខ្លឹមសារកម្មវិធី និងក្រេឌីតដើម្បីធានាឱ្យបាននូវសង្គតិភាព ការប្រៀបធៀបបាន និងការបន្សុីគ្នានូវគ្រប់កម្មវិធីនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀនទាំងអស់។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

កម្មវិធីអប់រំគ្រូបង្រៀននីមួយៗមានជម្រើសបន្ថែមក្នុងការរួមបញ្ចូល ***សកម្មភាពក្រៅកម្មវិធីអប់រំ*** ដោយផ្អែកលើតម្រូវការរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀនសម្រាប់សកម្មភាពក្រៅម៉ោងសិក្សា។ គ្រឹះស្ថានអប់រំគ្រូបង្រៀនផ្តល់ក្រេឌីតសកម្មភាពក្រៅកម្មវិធីអប់រំជាក្រេឌីតបន្ថែមទៅលើបណ្តុំមុខវិជ្ជាសិក្សាចំនួន៥ខាងលើ។

និយមន័យ និងសនិទានកម្មនៃបណ្តុំមុខវិជ្ជាសិក្សានីមួយៗមានដូចខាងក្រោម៖

### ៧.១ ការសិក្សាពីការអប់រំ[2]

ការសិក្សាពីការអប់រំគ្របដណ្តប់លើមុខវិជ្ជាសិក្សាទាំងអស់ ដែលផ្តល់ឱ្យគរុនិស្សិតនូវការយល់ដឹងជាក់ស្តែងពីបញ្ញត្តិ និងគោលការណ៍សំខាន់ៗនៃការអប់រំដែលចាំបាច់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការអនុវត្តការឆ្លុះបញ្ចាំងនៅតាមសាលារៀន។ លើសពីនេះ គរុនិស្សិតនឹងមានឱកាសសិក្សាស៊ីជម្រៅលើទិដ្ឋភាពសំខាន់ៗមួយចំនួននៃការអប់រំផងដែរ។

គោលបំណងនៃបណ្តុំមុខវិជ្ជាសិក្សាការសិក្សាពីការអប់រំ ដើម្បីបំពាក់ឱ្យគរុនិស្សិតនូវចំណេះដឹងអនុវត្តទូលំទូលាយពាក់ព័ន្ធវិធីសាស្ត្រទូទៅក្នុងការបង្រៀនសិស្សនៅកម្រិតសាលារៀនរួមជាមួយការយល់ដឹងអំពីបញ្ហាដែលជះឥទ្ធិពលដល់ការបង្រៀននិងរៀន។

ឧទាហរណ៍នៃប្រធានបទមូលដ្ឋាន និងបន្ថែមដែលត្រូវចាត់ថ្នាក់ក្រោមបណ្តុំមុខវិជ្ជាសិក្សា ការសិក្សាពីការអប់រំរួមមាន៖

- ការបង្រៀន និងការគ្រប់គ្រងសិស្ស
- ចិត្តវិទ្យាអប់រំ (ចិត្ត-គរុកោសល្យ)
- ការរៀបចំកិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស
- ការអនុវត្តក្នុងថ្នាក់រៀន
- ការរៀបចំកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត
- ការវាយតម្លៃការរៀន និងការអនុវត្ត
- ការប្រតិបត្តិវិជ្ជាជីវៈ និងការរិះរក
- ការងារគ្រប់គ្រងអប់រំ និងរដ្ឋបាលអប់រំ
- បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការរៀននិងបង្រៀន
- ខ្លឹមសារណែនាំអំពីកម្មវិធីអន្តរវិស័យក្នុងការងារអប់រំ៖
  - ការអប់រំបរិយាបន្ន
  - សាលាកុមារមេត្រី
  - បំណិនសតវត្សរ៍ទី២១
  - ការបង្រៀនថ្នាក់គួប
  - ការអប់រំសម្រាប់សិស្សមានតម្រូវការពិសេស
  - យេនឌ័រ និងការអប់រំ
  - ពិការភាព និងការអប់រំ

[2] បំណិនវិជ្ជាជីវៈ (កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១)

- គោលនយោបាយ និងការអនុវត្តការអប់រំពហុភាសា
- ការអប់រំជនជាតិដើមភាគតិច-ចំណេះដឹង គំរូ និងវិធីសាស្ត្រ
- ការចូលរួមរបស់សហគមន៍

▪ ការសិក្សាពីបំណិនឧទ្ទេស-សរសេរ

ការសិក្សាពីបំណិនឧទ្ទេស-សរសេរជាមុខវិជ្ជាតម្រូវសម្រាប់ គរុនិស្សិតគ្រប់កម្រិតទាំងអស់ដែល ១) គរុនិស្សិតត្រូវសិក្សាពីពាក្យតម្រុយ និងវាក្យសព្ទសម្រាប់ការបង្រៀន និងគ្រប់គ្រងសិស្សនៅក្នុងថ្នាក់រៀន ២) គរុនិស្សិតនឹងអភិវឌ្ឍបំណិនភាសាវិទ្យា និងសិក្សាដែលត្រូវការក្នុងការស្រាវជ្រាវចូលនិងអានអត្ថបទសិក្សាអន្តរជាតិ រួមទាំងសរសេរ និងធ្វើបទបង្ហាញអត្ថបទនិងកិច្ចការតាមស្តង់ដាដែលបានកំណត់នៅកម្រិតឧត្តមសិក្សា និង ៣) គរុនិស្សិតនឹងសិក្សាពីជំនាញកុំព្យូទ័រមូលដ្ឋានដើម្បីធ្វើការស្រាវជ្រាវ ផលិតសម្ភារៈ ធ្វើបទបង្ហាញ និងប្រគល់កិច្ចការសំណេរ។

ផ្នែកមួយនៃការសិក្សាពីការអប់រំគឺ ដើម្បីឱ្យគរុនិស្សិតយល់ដឹងពីសកម្មភាពវិជ្ជាជីវៈយ៉ាងទូលំទូលាយដែលទាក់ទងនឹងការបង្រៀន។ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំបច្ចុប្បន្នរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអភិវឌ្ឍគ្រូបង្រៀន ការសិក្សាពីការអប់រំគ្របដណ្តប់លើប្រធានបទដូចជា៖

▪ គោលការណ៍ និងការអនុវត្តនៃការសិក្សាពេញមួយជីវិតសម្រាប់គ្រូបង្រៀន
▪ បំណិនសតវត្សរ៍ទី២១ សម្រាប់គ្រូបង្រៀន
▪ យន្តការនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់ការបណ្តុះបណ្តាលនៅតាមសាលារៀន

### ៧.២ ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស [3]

ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេសគ្របដណ្តប់លើមុខវិជ្ជាសិក្សាទាំងឡាយណាដែលផ្តល់ឱ្យគរុនិស្សិតនូវការណែនាំអំពីខ្លឹមសារ បញ្ញត្តិ និងគោលការណ៍នៃមុខវិជ្ជាដូចដែលមាននៅក្នុងកម្មវិធីសិក្សាមូលដ្ឋានសម្រាប់កម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

មុខវិជ្ជាសិក្សានៃបណ្តុំមុខវិជ្ជាចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស ពង្រឹងចំណេះដឹងគរុនិស្សិតលើខ្លឹមសារមុខវិជ្ជាទាំងអស់សម្រាប់ការបង្រៀននៅកម្រិតសាលារៀន។

គោលបំណងនៃបណ្តុំមុខវិជ្ជាសិក្សាចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស ដើម្បីផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេសដែលត្រូវការសម្រាប់បង្រៀននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិដោយផ្អែកលើប្រធានបទដែលមាននៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។ គោលបំណងនៃមុខវិជ្ជាសិក្សាទាំងនេះ ដើម្បីផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង ឬបំណិនមានកម្រិតខ្ពស់ជាងកម្មវិធីសិក្សាថ្នាក់ទី១២ ដែលជាតម្រូវការសញ្ញាបត្រនៅឧត្តមសិក្សា ឬថ្នាក់ក្រោយបរិញ្ញាបត្រ។

ឧទាហរណ៍នៃប្រធានបទមូលដ្ឋាន និងបន្ថែមដែលត្រូវចាត់ថ្នាក់ក្រោមបណ្តុំមុខវិជ្ជាសិក្សាចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេសរួមមាន៖

▪ មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាភាសាអង់គ្លេស

---

[3] ចំណេះដឹងមូលដ្ឋាន (កម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១ និងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា ១២+២ តាមប្រព័ន្ធក្រេឌីតឆ្នាំ២០១៧) ចំណេះដឹងលើមុខវិជ្ជា (កម្មវិធីអប់រំកម្រិតបឋមសិក្សារបស់វិទ្យាស្ថានគរុកោសល្យឆ្នាំ២០២១) និងចំណេះដឹងលើមុខវិជ្ជាឯកទេស (កម្មវិធីអប់រំកម្រិតមធ្យមសិក្សាបឋមភូមិរបស់វិទ្យាស្ថានគរុកោសល្យឆ្នាំ២០២១ និងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ ១២+២ ឆ្នាំ២០១៩)។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាគណិតវិទ្យា
- មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាវិទ្យាសាស្ត្រ (រួមទាំងរូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ផែនដីវិទ្យានិងបរិស្ថាន)
- មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាសិក្សាសង្គម (រួមទាំងភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិជ្ជា )
- មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាភាសា (រួមទាំងភាសាខ្មែរ និងបារាំង)
- មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាអប់រំសិល្បៈ
- មូលដ្ឋានគ្រឹះ និងប្រធានបទបន្ថែមនៃមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ល។

## ៧.៣ ការសិក្សាពីកម្មវិធីសិក្សា[4]

ការសិក្សាពីកម្មវិធីសិក្សាគ្របដណ្ដប់លើមុខវិជ្ជាសិក្សាដែលផ្ដល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងបំណិនគរុកោសល្យដែលទាក់ទងនឹងការបង្រៀនមុខវិជ្ជាជាក់លាក់នៅតាមសាលារៀន ស្របតាមតម្រូវការនៃកម្មវិធីសិក្សាមូលដ្ឋាននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ។

មុខវិជ្ជាសិក្សានៃការសិក្សាពីកម្មវិធីសិក្សាផ្ដល់ឱ្យគរុនិស្សិត នូវវិធីសាស្ត្របង្រៀនលើមុខវិជ្ជានៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ។ គរុនិស្សិតនឹងបង្កើនការយល់ដឹងអំពីតម្រូវការនៃកម្មវិធីសិក្សាតាមមុខវិជ្ជា និងអភិវឌ្ឍវិធីសាស្ត្របង្រៀនសមស្រប។ មុខវិជ្ជាសិក្សានៃការសិក្សាពីកម្មវិធីសិក្សាក៏នឹងផ្ដល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងវិធីសាស្ត្របង្រៀនសម្រាប់ការបង្រៀនអំណាន និងគណិតវិទ្យាដំបូងនៅបឋមសិក្សា។

គោលបំណងនៃមុខវិជ្ជាសិក្សានៃការសិក្សាពីកម្មវិធីសិក្សា ដើម្បីជួយគរុនិស្សិតអភិវឌ្ឍបំណិនគរុកោសល្យដែលត្រូវការសម្រាប់ការធ្វើកិច្ចតែងការ ការបង្រៀន និងការវាយតម្លៃតាមមុខវិជ្ជានៅកម្រិតសាលារៀន។

## ៧.៤ កម្មសិក្សាគរុកោសល្យ

កម្មសិក្សាគរុកោសល្យ គ្របដណ្ដប់លើសមាសភាគនៃការសិក្សាដែលត្រូវបានទទួលស្គាល់ដោយគរុនិស្សិតត្រូវបានផ្សារភ្ជាប់ជាមួយសាលារៀនដើម្បីទទួលបានបទពិសោធន៍ និងការយល់ដឹងអំពីគ្រប់ទិដ្ឋភាពនៃការបង្រៀន។

សម្រាប់កម្មសិក្សាគរុកោសល្យ គរុនិស្សិតគ្រប់កម្រិតទាំងអស់នឹង ១) ទទួលបានបទពិសោធន៍ដំបូងនៃការបង្រៀន ២) អភិវឌ្ឍ និងអនុវត្តបំណិនបង្រៀនប្រតិបត្តិជាក់ស្តែង (ការធ្វើកិច្ចតែងការបង្រៀន ការរៀបចំសកម្មភាព និងការគ្រប់គ្រងថ្នាក់រៀន) ៣) ស្រាវជ្រាវ និងស្វែងរកវិធីផ្សេងៗក្នុងការដោះស្រាយតម្រូវការសិស្ស និង ៤) ចូលរួម និងសិក្សាពីមិត្តរួមក្រុម និងអ្នកប្រឹក្សាគរុកោសល្យរួមទាំងគ្រូបង្រៀន និងគ្រូណែនាំដែលមានបទពិសោធន៍។

គោលបំណងនៃកម្មសិក្សាគរុកោសល្យ ដើម្បីណែនាំគរុនិស្សិតអំពីបរិស្ថានសាលារៀន កសាងទំនុកចិត្តរបស់ពួកគេក្នុងថ្នាក់រៀន អភិវឌ្ឍសមត្ថភាពបង្រៀនរបស់ពួកគេក្នុងបរិបទផ្សេងៗគ្នា និងបង្កើតវិធីសាស្ត្រស្វ័យឆ្លុះបញ្ចាំង លើការបង្រៀន និងរៀន។ លើសពីនេះ កម្មសិក្សាគរុកោសល្យផ្ដល់ឱ្យគរុនិស្សិតនូវការយល់ដឹងកាន់តែទូលំទូលាយពីការគ្រប់គ្រងសាលារៀន ទំនាក់ទំនងជាមួយសហគមន៍ និងការទទួលខុសត្រូវលើវិជ្ជាជីវៈរបស់ខ្លួន។

---

[4] ចំណេះដឹង និងវិធីសាស្ត្របង្រៀនថ្នាក់មត្តេយ្យសិក្សា (កម្មវិធីបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១) និងវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា១២+២ តាមប្រព័ន្ធក្រេឌីតឆ្នាំ២០១៧)។

សកម្មភាពនៃបណ្ដុំមុខវិជ្ជាកម្មសិក្សាគរុកោសល្យមានដូចខាងក្រោម៖

- ការដកស្រង់បទពិសោធន៍នៅសាលារៀន៖
  - សកម្មភាពសង្កេតថ្នាក់រៀន
  - ធ្វើការឆ្លុះបញ្ចាំងជាប្រចាំ
- ភាពជាអ្នកជំនួយការបង្រៀន៖
  - ជំនួយការបង្រៀនក្នុងថ្នាក់
  - បង្រៀនក្នុងថ្នាក់ដោយមានការណែនាំពីគ្រូណែនាំ
  - ធ្វើការជាមួយមិត្តរួមក្រុមក្នុងគ្រឹះស្ថានអប់រំគ្រូបង្រៀន និងគ្រូណែនាំនៅសាលារៀន
  - ធ្វើការឆ្លុះបញ្ចាំងជាប្រចាំ
- ការអនុវត្តការបង្រៀនជាក់ស្ដែង៖
  - រៀបចំកិច្ចតែងការបង្រៀន
  - អនុវត្តការបង្រៀន
  - ឆ្លុះបញ្ចាំងលើការអនុវត្តវិជ្ជាជីវៈ
  - អនុវត្តការស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់រៀន
  - សកម្មភាពគាំទ្រពីមិត្តរួមក្រុមនៅសាលារៀន

## ៧.៥ ការស្រាវជ្រាវ[5]

ការស្រាវជ្រាវ គ្របដណ្ដប់មុខវិជ្ជាបង្រៀន និងសកម្មភាពដែលត្រូវបានទទួលស្គាល់ទាក់ទងនឹងការអនុវត្តការស្រាវជ្រាវនិងអនុវត្តការស្រាវជ្រាវអប់រំ។ សមាសភាគការស្រាវជ្រាវរួមមាន មុខវិជ្ជាបង្រៀន និងគម្រោងស្រាវជ្រាវប្រតិបត្តិ។

ក្នុងមុខវិជ្ជាបង្រៀនពីការស្រាវជ្រាវ គរុនិស្សិតគ្រប់កម្រិតនឹងទទួលបានចំណេះដឹងអំពីគោលបំណង ដំណើរការ និងគុណតម្លៃនៃការស្រាវជ្រាវពីការសិក្សា និងការស្រាវជ្រាវប្រតិបត្តិនៅក្នុងបរិបទនៃការអប់រំកម្រិតសាលារៀន។ ពួកគេនឹងអភិវឌ្ឍជំនាញក្នុងការរៀបចំការស្រាវជ្រាវ ប្រមូលនិងវិភាគទិន្នន័យ បកស្រាយលទ្ធផល និងការធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវ។ ការស្រាវជ្រាវគឺជាកាតព្វកិច្ចសម្រាប់គរុនិស្សិតទាំងអស់ក្នុងការធ្វើការស្រាវជ្រាវប្រតិបត្តិដើម្បីបំពេញលក្ខខណ្ឌក្នុងការបញ្ចប់ការអប់រំ។ គរុនិស្សិតត្រូវរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិដែលមានការទទួលស្គាល់ទាក់ទងនឹងការអនុវត្តការបង្រៀនផ្ទាល់ និងស្របតាមបរិបទសាលារៀនដែលពួកគេចុះកម្មសិក្សាគរុកោសល្យ។

គោលបំណងនៃសមាសភាគការស្រាវជ្រាវ ផ្ដល់ឱ្យគរុនិស្សិតគ្រប់កម្រិតនូវការប្រតិបត្តិវិជ្ជាជីវៈនៃការស្រាវជ្រាវ និងពិនិត្យការអនុវត្តការបង្រៀនដើម្បីកំណត់ផ្នែកដែលត្រូវកែលម្អ។

## ៧.៦ សកម្មភាពក្រៅកម្មវិធីអប់រំ

គ្រឹះស្ថានអប់រំគ្រូបង្រៀនមានជម្រើសក្នុងការបញ្ចូលសកម្មភាពក្រៅកម្មវិធីអប់រំ បន្ថែមពីលើបណ្ដុំមុខវិជ្ជាសិក្សាទាំង៥ដែលបានពណ៌នាខាងលើ។

---

[5] ស្រាវជ្រាវគរុកោសល្យ (កម្មវិធីបណ្ដុះបណ្ដាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១ កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា១២+២ តាមប្រព័ន្ធក្រេឌីតឆ្នាំ២០១៧ និងកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ ១២+២ ឆ្នាំ២០១៩)។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការបញ្ចូលសកម្មភាពក្រៅកម្មវិធីអប់រំគឺផ្អែកលើតម្រូវការរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។ ជាទូទៅ សកម្មភាពក្រៅកម្មវិធីអប់រំអាចរួមបញ្ចូលកិច្ចការ និងសកម្មភាពដែលទាក់ទងនឹងការកសាងទំនាក់ទំនងក្នុងសង្គម សុខភាពផ្លូវកាយ ឬសុខុមាលភាពផ្លូវចិត្ត។

ឧទាហរណ៍ខាងក្រោមនេះជាសកម្មភាពក្រៅកម្មវិធីអប់រំ៖

- អប់រំកាយ កីឡា ចិត្តចលភាព
- ព្រឹត្តិការណ៍កីឡា និងកីឡា
- សកម្មភាព និងព្រឹត្តិការណ៍បែបច្នៃប្រឌិត (ឧទាហរណ៍ ការសម្តែង និងសិល្បៈ)
- សកម្មភាពចូលរួមសហគមន៍
- សកម្មភាពសប្បុរសធម៌ ឬការកៀរគរថវិកា
- ព្រឹត្តិការណ៍សង្គម
- ការសម្អាតបរិវេណសាលារៀន និងថ្នាក់រៀន។ល។

ក្រេឌីតដែលទទួលបានពីសកម្មភាពក្រៅកម្មវិធីអប់រំ ជាក្រេឌីតបន្ថែមលើក្រេឌីតសិក្សានៃបណ្តុំមុខវិជ្ជាសិក្សាទាំង៥ ដែលបានបញ្ជាក់ខាងលើ និងមានចំនួនសរុបមិនលើសពី ២ក្រេឌីតក្នុងមួយឆ្នាំសិក្សា។

## ៨. ប្រភេទមុខវិជ្ជាសិក្សា

កម្មវិធីអប់រំគ្រូបង្រៀននីមួយៗមានប្រភេទមុខវិជ្ជាសិក្សាដូចខាងក្រោម៖

- មុខវិជ្ជាសិក្សាស្នូល
- មុខវិជ្ជាសិក្សាកាតព្វកិច្ច
- មុខវិជ្ជាសិក្សាជម្រើស

រាល់មុខវិជ្ជាសិក្សា ឬសកម្មភាពដែលត្រូវបានទទួលស្គាល់នៃកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់នឹងត្រូវបានចាត់ចូលក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទមុខវិជ្ជាសិក្សាទាំងបីនេះ។ ដើម្បីធានាបាននូវសង្គតិភាព ការប្រៀបធៀបបាន និងការបន្សីគ្នាគ្រប់កម្មវិធីនិងគ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រឹះស្ថានអប់រំគ្រូបង្រៀនទាំងអស់នៅក្នុងប្រព័ន្ធអប់រំគ្រូបង្រៀនកម្ពុជាត្រូវប្រើប្រាស់ប្រភេទមុខវិជ្ជាសិក្សាទាំងបីនេះនៅក្នុងការរៀបចំ បែងចែកមុខវិជ្ជាសិក្សានៃកម្មវិធីអប់រំ និងកម្មវិធីអប់រំលម្អិត។

ការបែងចែកប្រភេទនៃមុខវិជ្ជាសិក្សានីមួយៗជាមុខវិជ្ជាសិក្សាស្នូល មុខវិជ្ជាសិក្សាកាតព្វកិច្ច ឬមុខវិជ្ជាសិក្សាជម្រើស នឹងត្រូវកំណត់ក្នុងដំណើរការរៀបចំកម្មវិធីអប់រំសម្រាប់កម្មវិធីអប់រំគ្រូបង្រៀននីមួយៗ។ ក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំសេចក្តីណែនាំរួមស្តីពីការបែងចែកប្រភេទនៃមុខវិជ្ជាសិក្សាជាពិសេសសម្រាប់មុខវិជ្ជាសិក្សាស្នូលដើម្បីធានាបានសង្គតិភាពរវាងកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់។

### ៨.១ មុខវិជ្ជាសិក្សាស្នូល

"មុខវិជ្ជាសិក្សាស្នូល" ជាមុខវិជ្ជាសិក្សា ឬសកម្មភាពត្រូវបានទទួលស្គាល់ ដែលជាមុខវិជ្ជាតម្រូវឱ្យសិក្សានៅក្នុងកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់។ មុខវិជ្ជាសិក្សាស្នូលរួមមាន[6]៖

- មុខវិជ្ជាសិក្សាទាំងឡាយណាដែលជាចំណេះដឹងមូលដ្ឋានសម្រាប់គ្រូបង្រៀនគ្រប់កម្រិតទាំងអស់។ ឧទាហរណ៍ មុខវិជ្ជាសិក្សាមូលដ្ឋាន ឬមុខវិជ្ជាសិក្សាតម្រង់ទិសដែលមានលក្ខណៈរួមនៅគ្រប់កម្រិតនៃការបង្រៀន។ ជាទូទៅមុខវិជ្ជាទាំងអស់នេះអាចមាននៅក្នុងបណ្តុំមុខវិជ្ជាសិក្សាការសិក្សាពីការអប់រំ

[6] ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនផ្តល់តែឧទាហរណ៍ទូទៅនៃប្រភេទមុខវិជ្ជាសិក្សាស្នូល កាតព្វកិច្ច និងជម្រើស។

- មុខវិជ្ជាសិក្សា សមាសភាគ ឬសកម្មភាពដែលត្រូវបានទទួលស្គាល់ ជាបុរេលក្ខខណ្ឌតម្រូវដើម្បីបញ្ចប់ការសិក្សាដោយមិនគិតពីកម្រិតនៃការបង្រៀន។ ឧទាហរណ៍ មុខវិជ្ជាសិក្សា សមាសភាគ ឬសកម្មភាព ដែលមានលក្ខណៈរួមនៅគ្រប់កម្រិតនៃការបង្រៀន។ មុខវិជ្ជាសិក្សា សមាសភាគ ឬសកម្មភាពទាំងអស់នេះអាចមាននៅក្នុងបណ្តុំមុខវិជ្ជាសិក្សាការសិក្សាពីការអប់រំ កម្មសិក្សាគរុកោសល្យ និងការស្រាវជ្រាវ។

## ៨.២ មុខវិជ្ជាសិក្សាកាតព្វកិច្ច

"មុខវិជ្ជាសិក្សាកាតព្វកិច្ច" ជាមុខវិជ្ជាសិក្សា សមាសភាគ ឬសកម្មភាពត្រូវបានទទួលស្គាល់ ដែលជាមុខវិជ្ជាតម្រូវឱ្យសិក្សានៅក្នុងកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ។ មុខវិជ្ជាសិក្សាកាតព្វកិច្ចរួមមាន៖

- មុខវិជ្ជាសិក្សា ដែលគ្របដណ្តប់លើខ្លឹមសារគរុកោសល្យ ឬកម្មវិធីសិក្សាមូលដ្ឋានជាក់លាក់សម្រាប់គ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ។ ឧទាហរណ៍ មុខវិជ្ជាសិក្សាមូលដ្ឋាន ឬមុខវិជ្ជាសិក្សាតម្រង់ទិសកម្រិតជាក់លាក់ណាមួយដែលស្ថិតនៅក្រោមបណ្តុំមុខវិជ្ជាសិក្សាការសិក្សាពីការអប់រំ ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស ឬការសិក្សាពីកម្មវិធីសិក្សា។
- មុខវិជ្ជាសិក្សាដែលតម្រូវដើម្បីបញ្ចប់ការអប់រំជាគ្រូបង្រៀនដែលមានឯកទេសលើមុខវិជ្ជាជាក់លាក់ណាមួយ (ឧទាហរណ៍ វិទ្យាសាស្ត្រ ភាសា សិល្បៈ។ ល។)។

## ៨.៣ មុខវិជ្ជាសិក្សាជម្រើស

"មុខវិជ្ជាសិក្សាជម្រើស" ជាមុខវិជ្ជាសិក្សា សមាសភាគ ឬសកម្មភាពត្រូវបានទទួលស្គាល់ ដែលគរុសិស្ស គរុនិស្សិតអាចជ្រើសរើសសិក្សា ដោយផ្អែកលើជំនាញវិជ្ជាជីវៈជាក់លាក់ ឬចំណាប់អារម្មណ៍របស់គរុនិស្សិតផ្ទាល់ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាក្នុងកម្មវិធីអប់រំគ្រូបង្រៀនជាក់លាក់ណាមួយកំណត់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន។

មុខវិជ្ជាសិក្សាជម្រើសរួមមាន៖

- ក្រោមបណ្តុំមុខវិជ្ជាសិក្សាការសិក្សាពីការអប់រំ៖
  - មុខវិជ្ជាសិក្សាបន្ថែមលើបញ្ហាអន្តរវិស័យជាក់លាក់ (ឧ. យេនឌ័រ ការអប់រំតម្រូវការពិសេស ការអប់រំបរិយាបន្ន ។ល។)
  - មុខវិជ្ជាសិក្សាបន្ថែមលើជំនាញវិជ្ជាជីវៈដូចជា ការអភិវឌ្ឍកម្មវិធីសិក្សា ការស្រាវជ្រាវកម្រិតថ្នាក់រៀន ការគ្រប់គ្រងសាលារៀន និងការវាយតម្លៃជាដើម។
- ក្រោមបណ្តុំមុខវិជ្ជាសិក្សាចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស៖
  - មុខវិជ្ជាសិក្សាបន្ថែមលើចំណេះដឹងមុខវិជ្ជាជាក់លាក់
  - មុខវិជ្ជាសិក្សាបន្ថែមលើការបន្សីខ្លឹមសារក្នុងក្រុមមុខវិជ្ជា (ឧ. វិទ្យាសាស្ត្រ មនុស្សសាស្ត្រ ភាសា ។ល។)
- ក្រោមបណ្តុំមុខវិជ្ជាសិក្សាការសិក្សាពីកម្មវិធីសិក្សា៖
  - មុខវិជ្ជាសិក្សាបន្ថែមជាក់លាក់លើមុខវិជ្ជាបង្រៀន និងការរៀន
  - មុខវិជ្ជាសិក្សាបន្ថែមលើខ្លឹមសារកម្មវិធីសិក្សាជាក់លាក់
  - មុខវិជ្ជាសិក្សាបន្ថែមលើការបង្រៀន និងរៀនអន្តរកម្មវិធី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ក្រោមបណ្ឌិតមុខវិជ្ជាសិក្សាការស្រាវជ្រាវ៖
  - មុខវិជ្ជាសិក្សាបន្ថែមលើការរៀបចំគម្រោងស្រាវជ្រាវនិងអនុវត្តការស្រាវជ្រាវ
  - មុខវិជ្ជាសិក្សាបន្ថែមលើការស្រាវជ្រាវ ផ្តោតលើគោលវិធីសិស្សមជ្ឈមណ្ឌល

## ៩. ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតបង្កើតឡើងដោយកំណត់អំពីកម្រិតវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលគរុនិស្សិតត្រូវទទួលបាន និងបង្ហាញឱ្យឃើញ នៅក្នុងដំណាក់កាលនីមួយៗនៃការអប់រំ។

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត គឺជាឯកសារយោងដ៏សំខាន់សម្រាប់អ្នកប្រើប្រាស់ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននេះ។

ផ្នែកនេះ ផ្តល់នូវសេចក្តីណែនាំសង្ខេបអំពីខ្លឹមសារ និងការរៀបចំឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត និងពន្យល់ពីរបៀបដែលឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតអាចយកទៅប្រើដើម្បីគាំទ្រការអភិវឌ្ឍកម្មវិធីអប់រំ។

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតត្រូវបានប្រើប្រាស់ដោយ ១) **គរុនិស្សិត** ដើម្បីណែនាំពួកគេពីគុណសម្បទាចាំបាច់ដែលពួកគេត្រូវមានព្រមទាំងជាមគ្គុទ្ទេសក៍ នៅក្នុងការសិក្សា និង ២) **អ្នកអភិវឌ្ឍកម្មវិធីអប់រំគ្រូបង្រៀន** គ្រប់កម្មវិធីអប់រំគ្រូបង្រៀន ក្នុងការរៀបចំអន្តរគមន៍សមស្របនានាដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា នៅដំណាក់កាលខុសគ្នានៃកម្មវិធីអប់រំ។

អ្នកអភិវឌ្ឍកម្មវិធីអប់រំគ្រូបង្រៀនត្រូវអនុវត្តតាមឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតនេះដើម្បី៖

- រៀបចំរចនាសម្ព័ន្ធកម្មវិធីអប់រំ តាមឆ្នាំសិក្សានីមួយៗ
- កំណត់អំពីមុខវិជ្ជា និងជ្រើសរើសខ្លឹមសារ សមស្របទៅតាមកម្រិតវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលរំពឹងទុក
- ជាមគ្គុទ្ទេសក៍ក្នុងការរៀបចំការប្រឡងប្រចាំឆ្នាំ ការវាយតម្លៃ និងឧបករណ៍វាយតម្លៃដទៃទៀត ដើម្បីធ្វើតេស្ត វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលត្រូវការនៅដំណាក់កាលនីមួយៗ។

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត ត្រូវបានបន្សីជាមួយស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នាពេលបច្ចុប្បន្ន។

ការប្រើប្រាស់ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត សម្រាប់ការរៀបចំកម្មវិធីអប់រំគ្រូបង្រៀនគ្រប់កម្រិតទាំងអស់ ត្រូវធានាថាគរុនិស្សិតដែលបញ្ចប់ការអប់រំបំពេញបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនតាមការកំណត់នៅកម្រិតគុណសម្បទាកម្រិតមូលដ្ឋាន ឬគុណសម្បទាកម្រិតខ្ពស់។

### ៩.១ រចនាសម្ព័ន្ធនៃឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត

រចនាសម្ព័ន្ធឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតផ្អែកលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងមានជាតុផ្សំសំខាន់ៗពីរគឺ សមាសភាគ និងដំណាក់កាល។

- សមាសភាគ បង្ហាញអំពីវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលគ្រូបង្រៀនចាំបាច់ត្រូវទទួលបាន
- ដំណាក់កាល បង្ហាញអំពីរបៀបដែលកម្មវិធីអប់រំនឹងអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា តាមដំណាក់កាល និងពេលវេលា។

#### ៩.១.១ សមាសភាគវិជ្ជាជីវៈគ្រូបង្រៀន

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតរួមមានសមាសភាគចំនួនបួនដែលផ្តោតទៅលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន៖

១. ចំណេះដឹងវិជ្ជាជីវៈ

២. ការប្រតិបត្តិវិជ្ជាជីវៈ

៣. ការសិក្សាវិជ្ជាជីវៈ

៤. សីលធម៌វិជ្ជាជីវៈ

សមាសភាគ សមាសភាគរង ស្តង់ដា និងសូចនាករនីមួយៗ គឺផ្អែកលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

### ៩.១.២ ដំណាក់កាលសិក្សា និងការអភិវឌ្ឍ

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត បង្ហាញអំពីដំណាក់កាលចំនួនពីរសម្រាប់ការអភិវឌ្ឍជំនាញពាក់ព័ន្ធនានា ធៀបជាមួយស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន សម្រាប់ការអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២។ ដំណាក់កាលទាំងពីរនេះ គឺបង្ហាញអំពីដំណាក់កាលដែលមានក្នុងការអប់រំគរុនិស្សិត។

ដំណាក់កាលនីមួយៗ ត្រូវបានបន្សុីជាមួយឆ្នាំសិក្សានៅក្នុងប្រព័ន្ធអប់រំគ្រូបង្រៀន៖

*តារាងទី 6៖ វេចនាសម្ព័ន្ធនៃសមត្ថភាពអប់រំគរុនិស្សិត ១២+២*

| ដំណាក់កាលសមត្ថភាពអប់រំគរុនិស្សិត | ឆ្នាំសិក្សា | សមត្ថភាព | វត្ថុបំណងនៃខ្លឹមសារ |
|---|---|---|---|
| ដំណាក់កាលទី ១ | ការអប់រំគ្រូបង្រៀនឆ្នាំទី១ | *សមត្ថភាពអប់រំ* | តម្រង់ទិសវិជ្ជាជីវៈ |
| ដំណាក់កាលទី ២ | ការអប់រំគ្រូបង្រៀនឆ្នាំទី២ | *សមត្ថភាពកម្រិតខ្ពស់* | ភាពផ្សេងៗគ្នារបស់សិស្ស |

ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត បង្ហាញអំពីដំណាក់កាលចំនួនបួនសម្រាប់ការអភិវឌ្ឍជំនាញពាក់ព័ន្ធនានា ធៀបជាមួយស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់ការអប់រំគ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤។ដំណាក់កាលទាំងបួននេះ គឺបង្ហាញអំពីដំណាក់កាលដែលមានក្នុងការអប់រំគរុនិស្សិត។

ដំណាក់កាលនីមួយៗ ត្រូវបានបន្សុីជាមួយឆ្នាំសិក្សានៅក្នុងប្រព័ន្ធអប់រំគ្រូបង្រៀន៖

*តារាងទី 7៖ វេចនាសម្ព័ន្ធនៃសមត្ថភាពអប់រំគរុនិស្សិត ១២+៤*

| ដំណាក់កាលសមត្ថភាពអប់រំគរុនិស្សិត | ឆ្នាំសិក្សា | សមត្ថភាព | វត្ថុបំណងនៃខ្លឹមសារ |
|---|---|---|---|
| ដំណាក់កាលទី ១ | ការអប់រំគ្រូបង្រៀនឆ្នាំទី១ | *សមត្ថភាពអប់រំ* | តម្រង់ទិសវិជ្ជាជីវៈ |
| ដំណាក់កាលទី ២ | ការអប់រំគ្រូបង្រៀនឆ្នាំទី២ | *សមត្ថភាពមូលដ្ឋាន* | ការអភិវឌ្ឍដោយដឹកដៃក្នុងនាមជាគ្រូបង្រៀន |
| ដំណាក់កាលទី ៣ | ការអប់រំគ្រូបង្រៀនឆ្នាំទី៣ | *សមត្ថភាពកម្រិតខ្ពស់* | ភាពផ្សេងៗគ្នារបស់សិស្ស |
| ដំណាក់កាលទី ៤ | ការអប់រំគ្រូបង្រៀនឆ្នាំទី៤ | *សមត្ថភាពចាប់ផ្តើម* | សាលារៀនជាអង្គភាពក្នុងការអភិវឌ្ឍ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដំណាក់កាលនីមួយៗនៃឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត សង្ខេបពីកម្រិតសមត្ថភាពដែលគរុនិស្សិតត្រូវបង្ហាញចេញមក ធៀបជាមួយសមាសភាគ សមាសភាគរង ស្តង់ដា និងសូចនាករនីមួយៗដែលកំណត់ដោយស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

### ៩.២ ការប្រើប្រាស់ឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិតសម្រាប់ការអភិវឌ្ឍកម្មវិធីអប់រំ

**យោងតាមឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត អ្នកអភិវឌ្ឍកម្មវិធីអប់រំត្រូវ៖**

- ប្រើប្រាស់សមាសភាគទាំងបួន និងសមាសភាគរងពាក់ព័ន្ធដើម្បីជ្រើសរើស ខ្លឹមសារសម្រាប់កម្មវិធីនីមួយៗ
- ប្រើប្រាស់ដំណាក់កាលពាក់ព័ន្ធ (១២+២៖ ដំណាក់កាល ១-២ និង ១២+៤៖ ដំណាក់កាល ១-៤ ដើម្បីរៀបចំរចនាសម្ព័ន្ធខ្លឹមសាររបស់កម្មវិធីអប់រំ)
- ប្រើប្រាស់ស្តង់ដា សូចនាករ និងគុណសម្បទាដើម្បីអភិវឌ្ឍខ្លឹមសារមុខវិជ្ជាសិក្សា និងសកម្មភាព
- ប្រើប្រាស់គុណសម្បទាដើម្បីតាក់តែងសំណួរប្រឡង កិច្ចការ និងឧបករណ៍វាយតម្លៃដទៃទៀត។

**នៅកម្រិតកម្មវិធី អ្នកអភិវឌ្ឍកម្មវិធីអប់រំត្រូវធានាឱ្យបានថា៖**

- កម្មវិធីសិក្សាត្រូវបានបន្សុីគ្នាជាមួយសមាសភាគ និងសមាសភាគរងនៃឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត
- កម្មវិធីអប់រំលម្អិត ត្រូវបន្សុីគ្នាជាមួយដំណាក់កាលនៃឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត។

**នៅកម្រិតមុខវិជ្ជាសិក្សា អ្នកអភិវឌ្ឍកម្មវិធីអប់រំត្រូវធានាឱ្យបានថា៖**

- ប្លង់មុខវិជ្ជាសិក្សានីមួយៗត្រូវបានបន្សុីជាមួយជម្រើសស្តង់ដា និងសូចនាករពាក់ព័ន្ធនៅក្នុងឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត
- សកម្មភាពរៀន និងបង្រៀនត្រូវបានបន្សុីជាមួយជម្រើសសមត្ថភាពនៅក្នុងឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត

**ក្នុងមុខវិជ្ជាសិក្សានីមួយៗ អ្នកអភិវឌ្ឍកម្មវិធីត្រូវធានាឱ្យបានថា៖**

- បទឧទ្ទេស សកម្មភាព ឬធនធាននីមួយៗត្រូវបានរៀបចំឡើងដើម្បីជួយគរុនិស្សិតឱ្យអភិវឌ្ឍគុណសម្បទាដែលរំពឹងទុក

**សម្រាប់ការវាយតម្លៃ (Assessment and Evaluation) អ្នកអភិវឌ្ឍកម្មវិធី ត្រូវធានាថា៖**

- រាល់ឧបករណ៍វាយតម្លៃនីមួយៗ (ឧទាហរណ៍៖ ការប្រឡង កិច្ចការ ឬលំហាត់) ត្រូវបានរៀបចំឡើងដើម្បីធ្វើតេស្តវាស់គុណសម្បទាគរុនិស្សិតនៅតាមដំណាក់កាលនីមួយៗនៃការសិក្សា។

## ១០. សនិទានភាពនៃការបន្សុីក្រេឌីតតាមកម្មវិធីអប់រំ

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនត្រូវបានរៀបចំឡើងដើម្បីគាំទ្រការបន្សុីក្រេឌីត នៅគ្រប់កម្មវិធីអប់រំគ្រូបង្រៀន។

ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនអាចសម្រេចបាននូវការបន្សុីក្រេឌីតតាមរយៈ ការប្រើប្រាស់ក្របខណ្ឌរួមនៃការគណនាក្រេឌីតកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ និង ១២+៤ ទាំងអស់។ ការបន្សុីក្រេឌីតនេះរួមបញ្ចូលការបន្សុីការបែងចែកក្រេឌីតសរុបសម្រាប់បណ្តុំមុខវិជ្ជាសិក្សានៃកម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ និង ១២+៤ ទាំងអស់។

ការបន្សុីក្រេឌីតនេះត្រូវធានាថាកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់នៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និង

មធ្យមសិក្សាបឋមភូមិ នឹងផលិតគ្រូបង្រៀនដែល៖

- មានស្តង់ដាវិជ្ជាជីវៈសមមូល
- អាចបង្ហាញពីកម្រិតគុណសម្បទាប្រហាក់ប្រហែលគ្នានៅក្នុងការបង្រៀន
- ក្លាយជាគ្រូបង្រៀនដែលមានកម្រិតសមមូល ក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ការប្រើប្រាស់ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀន ជាឯកសារយោងសម្រាប់ការរៀបចំកម្មវិធីអប់រំ កម្មវិធីអប់រំលម្អិត និងឯកសារមុខវិជ្ជាសិក្សា គ្រឹះស្ថានអប់រំគ្រូបង្រៀនត្រូវធានាថាគរុនិស្សិតទាំងអស់ដែលបានសិក្សាកម្មវិធីអប់រំគ្រូបង្រៀននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នឹងទទួលបាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាសមមូល លើមុខវិជ្ជាដូចខាងក្រោម៖

- គរុកោសល្យនិងវិធីសាស្ត្របង្រៀន
- ចំណេះដឹងតាមមុខវិជ្ជាឯកទេស
- ចំណេះដឹងវិជ្ជាជីវៈ
- កម្មសិក្សាគរុកោសល្យ
- ការស្រាវជ្រាវ
- មុខវិជ្ជាដទៃទៀត រួមមានការអប់រំបរិយាបន្ន សាលាកុមារមេត្រី បំណិនសតវត្សរ៍ទី២១ ការអប់រំពិសេស យេនឌ័រ និងការអប់រំពហុភាសាសម្រាប់ជនជាតិដើមភាគតិច។

គោលដៅសំខាន់នៃការបន្សុីក្រេឌីតនេះគឺ ជានាថាសិស្សានុសិស្សទាំងអស់នៅសាលារៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិទទួលបានគុណភាពក្នុងការសិក្សាស្មើៗគ្នា និងទទួលបានការបង្រៀនពីគ្រូបង្រៀនដែលទទួលបានការអប់រំស្របតាមស្តង់ដារួម សម្រាប់ឧត្តមភាពវិជ្ជាជីវៈ។

**ការបន្សុីក្រេឌីត និងផែនការ ការអប់រំគ្រូបង្រៀនថ្នាក់ជាតិ**

តាមរយៈការបន្សុី ការបែងចែកក្រេឌីតនៅគ្រប់កម្មវិធីអប់រំគ្រូបង្រៀន ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀនរួមចំណែកក្នុងការសម្រេចគោលបំណងស្តីពីការអភិវឌ្ឍកម្មវិធីអប់រំគ្រូបង្រៀន ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា និងផែនការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

ការបន្សុីក្រេឌីតនៃក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀននៅគ្រប់កម្មវិធីអប់រំគ្រូបង្រៀននឹងរួមចំណែកដល់ការសម្រេចបាននូវវត្ថុបំណងរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ រួមមាន៖

- ការណែនាំអំពីកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត
- ការពិនិត្យ និងកែលម្អកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ
- សុខដុមនីយកម្មនៃកម្មវិធីអប់រំគ្រូបង្រៀន និងស្តង់ដាអប់រំគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានអប់រំគ្រូបង្រៀនតាមរយៈ ១) ប្រព័ន្ធក្រេឌីត ២) រចនាសម្ព័ន្ធកម្មវិធីអប់រំ និង ៣) វិធីសាស្ត្របង្រៀន
- សង្គតិភាព និងភាពពាក់ព័ន្ធនៃការអភិវឌ្ឍសមត្ថភាពក្នុងការបង្រៀនកាន់តែប្រសើរឡើង។

## ១១. ក្របខណ្ឌកម្មវិធីអប់រំក្នុងការបែងចែកក្រេឌីត

ផ្នែកនេះ សង្ខេបព័ត៌មានលម្អិតនៃកម្មវិធីអប់រំនិង ក្របខណ្ឌសម្រាប់ការបែងចែកក្រេឌីតលើមុខវិជ្ជាសិក្សាដូចខាងក្រោម៖

- កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២ (អប្បបរមា ៦០ ក្រេឌីត)
- កម្មវិធីអប់រំគ្រូបឋមសិក្សាតាមប្រព័ន្ធ ១២+២ (អប្បបរមា ៦០ ក្រេឌីត)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ (អប្បបរមា ១២០ ក្រេឌីត)
- កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ (អប្បបរមា ៦០ ក្រេឌីត)
- កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ (អប្បបរមា ១២០ ក្រេឌីត)

ផ្នែកនេះរួមមានតារាងប្រៀបធៀបការបែងចែកក្រេឌីតនៅគ្រប់កម្មវិធីអប់រំទាំងអស់ (ផ្នែកទី ១១.២) និងសេចក្តីសង្ខេបនៃសនិទានភាពនៃការរៀបចំ ការបែងចែកក្រេឌីតសម្រាប់មុខវិជ្ជាសិក្សានីមួយៗ ដោយផ្អែកលើភស្តុតាងនៃតម្រូវការជាអាទិភាពរបស់គ្រូបង្រៀន ។

ក្របខណ្ឌកម្មវិធីអប់រំផ្តល់ឱ្យអ្នកអភិវឌ្ឍកម្មវិធីអប់រំនូវការណែនាំមូលដ្ឋានដើម្បីគាំទ្រដល់ការអភិវឌ្ឍ ១) កម្មវិធីអប់រំ ២) កម្មវិធីអប់រំលម្អិត និង ៣) ការជ្រើសរើសនិងលំដាប់លំដោយនៃមុខវិជ្ជាសិក្សានីមួយៗ។

ការបង្ហាញក្របខណ្ឌការបែងចែកក្រេឌីតសម្រាប់កម្មវិធីអប់រំនីមួយៗក្នុងឯកសារនេះ អាចធ្វើបច្ចុប្បន្នកម្ម និងកែសម្រួលបានផ្អែកលើការអភិវឌ្ឍជាបន្តបន្ទាប់ ព្រមទាំងការផ្តល់ជាតុចូលក្នុងការរៀបចំនៅកម្រិតកម្មវិធីអប់រំ និងកម្រិតកម្មវិធីអប់រំលម្អិត។

## ១១.១ ទិដ្ឋភាពទូទៅនៃការបែងចែកក្រេឌីត

### ១១.១.១ ការប្រៀបធៀបក្រេឌីតតាមកម្មវិធីអប់រំ

តារាងខាងក្រោមផ្តល់នូវទិដ្ឋភាពទូទៅក្នុងការប្រៀបធៀបការបែងចែកក្រេឌីតសម្រាប់កម្មវិធីអប់រំនីមួយៗ។ តារាងនេះបង្ហាញអំពីការបែងចែកក្រេឌីតតាមមុខវិជ្ជាសិក្សានីមួយៗ និងភាគរយនៃក្រេឌីតសរុប។ តារាងនេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញអំពីការបន្សុីនៅក្នុងកម្មវិធីអប់រំទាំងមូល និងជួយក្នុងការប្រៀបធៀបរវាងកម្មវិធីអប់រំតាមប្រព័ន្ធ ១២+២ និង១២+៤។

*តារាងទី ៥៖ សេចក្តីសង្ខេបពីការផ្តល់ក្រេឌីតនៅគ្រប់កម្មវិធីអប់រំតាមប្រព័ន្ធ ១២+២ និង១២+៤*

| ល.រ | មុខវិជ្ជាសិក្សា និង ការទទួលស្គាល់ | ការផ្តល់ក្រេឌីតតាមមុខវិជ្ជាសិក្សា | | | | |
|---|---|---|---|---|---|---|
| | | ១២+២ | | | ១២+៤ | |
| | | មត្តេយ្យសិក្សា | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ |
| ១ | ការសិក្សាពីការអប់រំ | ១៣ | ១៣ | ១៣ | ២៩ | ២៩ |
| ២ | ចំណេះដឹងមុខវិជ្ជា/មុខវិជ្ជាឯកទេស | ១២ | ១២ | ១៨ | ២២ | ៤៣ |
| ៣ | ការសិក្សាពីកម្មវិធីសិក្សា | ១៨ | ១៨ | ១២ | ៤១ | ២០ |
| ៤ | កម្មសិក្សាគរុកោសល្យ | ១២ | ១២ | ១២ | ២២ | ២២ |
| ៥ | ការស្រាវជ្រាវ | ៥ | ៥ | ៥ | ៦ | ៦ |
| | **ក្រេឌីតសរុប** | **៦០** | **៦០** | **៦០** | **១២០** | **១២០** |
| ៦ | សកម្មភាពក្រៅកម្មវិធីអប់រំ | *សូមមើលកំណត់សម្គាល់ ១១.១* | *សូមមើលកំណត់សម្គាល់ ១១.១* | *សូមមើលកំណត់សម្គាល់ ១១.១* | *សូមមើលកំណត់សម្គាល់ ១១.១* | *សូមមើលកំណត់សម្គាល់ ១១.១* |

### ១១.១.២ សនិទានភាពសម្រាប់ការផ្តល់ក្រេឌីតតាមបណ្តុំមុខវិជ្ជាសិក្សានីមួយៗ

សនិទានភាពសម្រាប់ការផ្តល់ក្រេឌីតតាមបណ្តុំ មុខវិជ្ជាសិក្សានីមួយៗមានដូចខាងក្រោម៖

- **ការសិក្សាពីការអប់រំ**

  អនុលោមតាមសនិទានភាពសម្រាប់ការបន្សីក្រេឌីតដូចបានពិភាក្សាក្នុងផ្នែកទី១០ កម្មវិធីអប់រំនីមួយៗ ត្រូវផ្តល់ក្រេឌីតសរុបស្មើគ្នាសម្រាប់បណ្តុំមុខវិជ្ជាសិក្សា **ការសិក្សាពីការអប់រំ។** បណ្តុំមុខវិជ្ជាសិក្សានេះ គ្របដណ្តប់ខ្លឹមសារស្នូលដែលមានតម្លៃ និងសារៈសំខាន់ស្មើគ្នាចំពោះគរុសិស្ស គរុនិស្សិតទាំងអស់ដែលនឹងទៅបង្រៀននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

- **ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស**

  បើប្រៀបធៀបរវាងកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សានិងបឋមសិក្សា កម្មវិធីអប់រំមធ្យមសិក្សាបឋមភូមិ មានក្រេឌីតខ្ពស់ជាងគេសម្រាប់ ***ចំណេះដឹងលើមុខវិជ្ជា*/មុខវិជ្ជាឯកទេស** ។ការផ្តល់ក្រេឌីតខ្ពស់ជាងគេនេះ គឺផ្អែកលើតម្រូវការដែលបានរកឃើញដើម្បីពង្រឹងចំណេះដឹងតាមមុខវិជ្ជាសម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ជាពិសេសគឺសម្រាប់មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ។

- **ការសិក្សាពីកម្មវិធីសិក្សា**

  កម្មវិធីអប់រំកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សាមានចំនួនក្រេឌីតខ្ពស់ជាងសម្រាប់បណ្តុំមុខវិជ្ជាសិក្សា **ការសិក្សាពីកម្មវិធីសិក្សា** ប្រសិនបើប្រៀបធៀបជាមួយកម្មវិធីអប់រំគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ ។ ការផ្តល់ក្រេឌីតខ្ពស់ជាងគេនេះ គឺផ្អែកលើតម្រូវការដែលបានកំណត់សម្រាប់គ្រូបង្រៀនកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សាក្នុងការទទួលបានចំណេះដឹងគរុកោសល្យ និងបច្ចេកទេសអប់រំច្រើនដើម្បីបង្រៀនសិស្សប្រកបដោយប្រសិទ្ធភាព ជាពិសេសសម្រាប់សិស្សនៅកម្រិតដំបូង។

- **កម្មសិក្សាគរុកោសល្យ**

  កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ ត្រូវផ្តល់សមាសភាគ***កម្មសិក្សាគរុកោសល្យ*** ប្រចាំឆ្នាំដែលមានចាប់ពី ៤ក្រេឌីត (១៨០ម៉ោង) ដល់ ៨ក្រេឌីត (៣៦០ម៉ោង) ក្នុងមួយឆ្នាំ។ កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ ផ្តល់សមាសភាគកម្មសិក្សាគរុកោសល្យ សរុប ១២ក្រេឌីត (៥៤០ម៉ោង)។ កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ ផ្តល់សមាសភាគកម្មសិក្សាគរុកោសល្យសរុប ២២ក្រេឌីត (៩៩០ម៉ោង)។

- **ការស្រាវជ្រាវ**

  នៅក្រោមសមាសភាគ **ស្រាវជ្រាវ** កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+២ ត្រូវផ្តល់សមាសភាគស្រាវជ្រាវដែលមានសរុប ៥ក្រេឌីត (មុខវិជ្ជាបង្រៀន ២ក្រេឌីត និងគម្រោងស្រាវជ្រាវប្រតិបត្តិ ៣ក្រេឌីត)។ កម្មវិធីអប់រំគ្រូបង្រៀនតាមប្រព័ន្ធ ១២+៤ ផ្តល់សមាសភាគការស្រាវជ្រាវដែលមានសរុប ៦ក្រេឌីត។

- **សកម្មភាពក្រៅកម្មវិធីអប់រំ**

  បន្ថែមលើក្រេឌីតសរុបដែលត្រូវផ្តល់ឱ្យសម្រាប់កម្មវិធីអប់រំនីមួយៗ (ប្រព័ន្ធ ១២+២ ដែលមាន ៦០ក្រេឌីត ១២+៤ ដែលមាន ១២០ក្រេឌីត) គ្រឹះស្ថានអប់រំគ្រូបង្រៀននីមួយៗមានជម្រើសផ្តល់ក្រេឌីតបន្ថែមសម្រាប់**សកម្មភាពក្រៅកម្មវិធីអប់រំ** ផ្អែកលើតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀនដែលជាសកម្មភាពមិនមាននៅក្នុងកាលវិភាគសិក្សា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ក្រេឌីតសម្រាប់សកម្មភាពក្រៅកម្មវិធីអប់រំជា ក្រេឌីតបំពេញបន្ថែមលើក្រេឌីតដែលបានកំណត់នៅក្នុងបណ្តុំមុខវិជ្ជាសិក្សាទី១-៥។ សម្រាប់កម្មវិធីនីមួយៗ ចំនួនក្រេឌីតសរុបនៃសកម្មភាពក្រៅកម្មវិធីអប់រំគឺមិនលើសពី ២ក្រេឌីត (៩០ ម៉ោង) ក្នុងមួយឆ្នាំសិក្សា។

### ១១.២ កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា

កម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២ សមមូលនឹង**បរិញ្ញាបត្ររង** ដែលមានរយៈពេលសិក្សា **២ឆ្នាំ** និងមានចំនួនក្រេឌីតសរុបអប្បបរមា **៦០ក្រេឌីត**។

ក្រៅពីតារាងខាងក្រោម ដំណើរការនៃការរៀបចំកម្មវិធីអប់រំនឹងសម្រេចចិត្តលើការបែងចែកក្រេឌីតទៅតាមបណ្តុំមុខវិជ្ជាសិក្សាក្នុងឆ្នាំនីមួយៗ។ សម្រាប់សនិទានភាពនៃការបែងចែកក្រេឌីតទៅលើបណ្តុំមុខវិជ្ជាសិក្សាទាំង៥ សូមមើលផ្នែក ១១.១ ខាងលើ។

*តារាងទី ១៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២*

| ល.រ | បណ្តុំមុខវិជ្ជាសិក្សា និងទទួលស្គាល់ | ក្រេឌីតសរុប | ឆ្នាំទី ១ | ឆ្នាំទី ២ |
|---|---|---|---|---|
| ១ | **ការសិក្សាពីការអប់រំ** | ១៣ | *១៣ ក្រេឌីត* | - |
| ២ | **ចំណេះដឹងមុខវិជ្ជា/មុខវិជ្ជាឯកទេស** | ១២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៣ | **ការសិក្សាពីកម្មវិធីសិក្សា** | ១៨ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៤ | **កម្មសិក្សាគរុកោសល្យ** | ១២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៥ | **ការស្រាវជ្រាវ** | ៥ | *២ ក្រេឌីត (មុខវិជ្ជាបង្រៀនពីការស្រាវជ្រាវ)* | *៣ ក្រេឌីត (គម្រោងស្រាវជ្រាវប្រតិបត្តិ)* |
| **សរុប** | | **៦០** | **៣០** | **៣០** |
| ៦ | **សកម្មភាពក្រៅកម្មវិធីអប់រំ** | *សូមមើលកំណត់សម្គាល់ផ្នែក ១១.១* | *សូមមើលកំណត់សម្គាល់ផ្នែក ១១.១* | *សូមមើលកំណត់សម្គាល់ផ្នែក ១១.១* |

### ១១.៣ កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២

កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២ គឺសមមូលនឹង**បរិញ្ញាបត្ររង** ដែលមានរយៈពេលសិក្សា **២ឆ្នាំ** និងមានចំនួនក្រេឌីតសរុបអប្បបរមា **៦០ក្រេឌីត**។

ក្រៅពីតារាងខាងក្រោម ដំណើរការនៃការរៀបចំកម្មវិធីអប់រំនឹងសម្រេចចិត្តលើការបែងចែកក្រេឌីតទៅតាមបណ្តុំមុខវិជ្ជាសិក្សាក្នុងឆ្នាំនីមួយៗ។ សម្រាប់សនិទានភាពនៃការបែងចែកក្រេឌីតទៅលើបណ្តុំមុខវិជ្ជាសិក្សាទាំង៥ សូមមើលផ្នែក ១១.១ ខាងលើ។

*តារាងទី 10៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២*

| ល.រ | បណ្ដុំមុខវិជ្ជាសិក្សា និងការទទួលស្គាល់ | ក្រេឌីតសរុប | ឆ្នាំទី ១ | ឆ្នាំទី ២ |
|---|---|---|---|---|
| ១ | **ការសិក្សាពីការអប់រំ** | ១៣ | *១៣ ក្រេឌីត* | - |
| ២ | **ចំណេះដឹងមុខវិជ្ជាឯកទេស** | ១២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៣ | **ការសិក្សាពីកម្មវិធីសិក្សា** | ១៨ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៤ | **កម្មសិក្សាគរុកោសល្យ** | ១២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៥ | **ការស្រាវជ្រាវ** | ៥ | *២ ក្រេឌីត (មុខវិជ្ជាបង្រៀនពីការស្រាវជ្រាវ)* | *៣ ក្រេឌីត(គម្រោងស្រាវជ្រាវប្រតិបត្តិ)* |
| **សរុប** | | **៦០** | **៣០** | **៣០** |
| ៦ | **សកម្មភាពក្រៅកម្មវិធីអប់រំ** | *សូមមើលកំណត់សម្គាល់ផ្នែក១១.១* | *សូមមើលកំណត់សម្គាល់ផ្នែក ១១.១* | *សូមមើលកំណត់សម្គាល់ផ្នែក ១១.១* |

### ១១.៤ កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២

កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ គឺសមមូលនឹង**បរិញ្ញាបត្ររង** ដែលមានរយៈពេលសិក្សា **២ឆ្នាំ** និងមានចំនួនក្រេឌីតសរុបអប្បបរមា **៦០ក្រេឌីត**។

ក្រៅពីតារាងខាងក្រោម ដំណើរការនៃការរៀបចំកម្មវិធីអប់រំនឹងសម្រេចចិត្តលើការបែងចែកក្រេឌីតទៅតាមបណ្ដុំមុខវិជ្ជាសិក្សាក្នុងឆ្នាំនីមួយៗ។ សម្រាប់សនិទានភាពនៃការបែងចែកក្រេឌីតទៅលើបណ្ដុំមុខវិជ្ជាសិក្សាទាំង៥ សូមមើលផ្នែក ១១.១ ខាងលើ។

*តារាងទី 11៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២*

| ល.រ | បណ្ដុំមុខវិជ្ជាសិក្សា និងការទទួលស្គាល់ | ក្រេឌីតសរុប | ឆ្នាំទី ១ | ឆ្នាំទី ២ |
|---|---|---|---|---|
| ១ | **ការសិក្សាពីការអប់រំ** | **១៣** | ១៣ ក្រេឌីត | - |
| ២ | **ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស** | **១៨** | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៣ | **ការសិក្សាពីកម្មវិធីសិក្សា** | ១២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៤ | **កម្មសិក្សាគរុកោសល្យ** | ១២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៥ | **ការស្រាវជ្រាវ** | **៥** | *២ ក្រេឌីត (មុខវិជ្ជាបង្រៀនពីការស្រាវជ្រាវ)* | *៣ ក្រេឌីត(គម្រោងស្រាវជ្រាវប្រតិបត្តិ)* |
| **សរុប** | | **៦០** | **៣០** | **៣០** |
| ៦ | **សកម្មភាពក្រៅកម្មវិធីអប់រំ** | *សូមមើលផ្នែក១១.១* | *សូមមើលផ្នែក១១.១* | *សូមមើលផ្នែក១១.១* |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១១.៥ កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤

កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ សមមូលនឹង**បរិញ្ញាបត្រ** ដែលមានរយៈពេលសិក្សា **៤ឆ្នាំ** និងមានចំនួនក្រេឌីតសរុបអប្បបរមា **១២០ក្រេឌីត**។

ក្រៅពីតារាងខាងក្រោម ដំណើរការនៃការរៀបចំកម្មវិធីអប់រំនឹងសម្រេចចិត្តលើការបែងចែកក្រេឌីតទៅតាមបណ្តុំមុខវិជ្ជាសិក្សាក្នុងឆ្នាំនីមួយៗ។ សម្រាប់សនិទានភាពនៃការបែងចែកក្រេឌីតទៅលើបណ្តុំមុខវិជ្ជាសិក្សាទាំង៥ សូមមើលផ្នែក ១១.១ ខាងលើ។

*តារាងទី 12៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤*

| ល.រ | បណ្តុំមុខវិជ្ជាសិក្សា និងការទទួលស្គាល់ | ក្រេឌីតសរុប | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ |
|---|---|---|---|---|---|---|
| ១ | **ការសិក្សាពីការអប់រំ** | ២៩ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | - | - |
| ២ | **ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស** | ២២ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៣ | **ការសិក្សាពីកម្មវិធីសិក្សា** | ៤១ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៤ | **កម្មសិក្សាគរុកោសល្យ** | ២២ | *២ ក្រេឌីត* | *៥ ក្រេឌីត* | *៥ ក្រេឌីត* | *១០ ក្រេឌីត* |
| ៥ | **ការស្រាវជ្រាវ** | ៦ | - | - | *៣ ក្រេឌីត* | *៣ ក្រេឌីត* |
| | **សរុប** | **១២០** | **៣០** | **៣០** | **៣០** | **៣០** |
| ៦ | **សកម្មភាពក្រៅកម្មវិធីអប់រំ** | *សូមមើលផ្នែក ១១.១* | *សូមមើលផ្នែក ១១.១* | *សូមមើលផ្នែក ១១.១* | *សូមមើលផ្នែក ១១.១* | *សូមមើលផ្នែក ១១.១* |

## ១១.៦ កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤

កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ សមមូលនឹង**បរិញ្ញាបត្រ** ដែលមានរយៈពេលសិក្សា **៤ឆ្នាំ** និងមានចំនួនក្រេឌីតសរុបអប្បបរមា **១២០ក្រេឌីត**។

ក្រៅពីតារាងខាងក្រោម ដំណើរការនៃការរៀបចំកម្មវិធីអប់រំនឹងសម្រេចចិត្តលើការបែងចែកក្រេឌីតទៅតាមបណ្តុំមុខវិជ្ជាសិក្សាក្នុងឆ្នាំនីមួយៗ។ សម្រាប់សនិទានភាពនៃការបែងចែកក្រេឌីតទៅលើបណ្តុំមុខវិជ្ជាសិក្សាទាំង៥ សូមមើលផ្នែក ១១.១ ខាងលើ។

*តារាងទី 13៖ ក្របខណ្ឌការបែងចែកក្រេឌីត ការអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤*

| ល.រ | បណ្តុំមុខវិជ្ជាសិក្សា និងការទទួលស្គាល់ | ក្រេឌីតសរុប | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ |
|---|---|---|---|---|---|---|
| ១ | **ការសិក្សាពីការអប់រំ** | ២៩ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | - | - |
| ២ | **ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស** | ៤៣ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៣ | **ការសិក្សាកម្មវិធីសិក្សា** | ២០ | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* | *ចំនួនក្រេឌីតសម្រេចនៅកម្រិតកម្មវិធីអប់រំ* |
| ៤ | **កម្មសិក្សាគរុកោសល្យ** | ២២ | *២ ក្រេឌីត* | *៥ ក្រេឌីត* | *៥ ក្រេឌីត* | *១០ ក្រេឌីត* |
| ៥ | **ការស្រាវជ្រាវ** | ៦ | - | - | *៣ ក្រេឌីត* | *៣ ក្រេឌីត* |
| **សរុប** | | **១២០** | **៣០** | **៣០** | **៣០** | **៣០** |
| ៦ | **សកម្មភាពក្រៅកម្មវិធីអប់រំ** | *សូមមើលផ្នែក ១១.១* | *សូមមើល ផ្នែក១១.១* | *សូមមើលផ្នែក ១១.១* | *សូមមើលផ្នែក ១១.១* | *សូមមើលផ្នែក ១១.១* |

## ១២. យន្តការវាយតម្លៃ

ផ្នែកនេះបង្ហាញនូវទិដ្ឋភាពទូទៅនៃយន្តការវាយតម្លៃនៃកម្មវិធីអប់រំគ្រូបង្រៀនរួមមាន។ សេចក្តីលម្អិតរួមមាន៖

- គោលបំណងនៃការវាយតម្លៃកម្មវិធីអប់រំគ្រូបង្រៀន
- ប្រព័ន្ធដាក់ពិន្ទុ និងនិទ្ទេស
- ក្របខណ្ឌនៃការវាយតម្លៃ៖
  - មុខវិជ្ជាបង្រៀន
  - កម្មសិក្សាគរុកោសល្យ
  - ការស្រាវជ្រាវ

### ១២.១ គោលបំណងនៃការវាយតម្លៃ

ការវាយតម្លៃកម្មវិធីអប់រំគ្រូបង្រៀនមានគោលបំណងសំខាន់ៗបី៖

១. វាស់វែងវឌ្ឍនភាពរបស់គរុនិស្សិត

២. អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គរុនិស្សិតដើម្បីបម្រើការនៅតាមសាលារៀន

៣. វាយតម្លៃភាពឆ្លើយតបនៃខ្លឹមសារមុខវិជ្ជានិងសកម្មភាពទៅនឹងគោលបំណងនៃកម្មវិធីអប់រំ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការរៀបចំកិច្ចការវាយតម្លៃត្រូវ៖

- ផ្តោតលើការអភិវឌ្ឍ និងការធ្វើតេស្តលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលគរុនិស្សិតត្រូវការដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការ ការសិក្សារបស់សិស្ស
- ជំរុញគរុនិស្សិតឱ្យសិក្សាតាមរយៈការអនុវត្តផ្ទាល់ ដូចជាការធ្វើតេស្តលើវិធីសាស្ត្របង្រៀនថ្មី និងវាយតម្លៃផលជះលើការសិក្សារបស់សិស្ស
- ជួយគរុនិស្សិត ក្នុងការអភិវឌ្ឍការយល់ដឹង ការអនុវត្តនិងការវាយតម្លៃ វិធីសាស្ត្របង្រៀនថ្មីៗ នៅក្នុងបរិបទសាលារៀន
- តម្រូវឱ្យគរុនិស្សិតចូលរួមក្នុងការតាមដាន និងចងក្រងឯកសារសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួនលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា និងបទពិសោធន៍ដែលបានទទួល ទាំងផ្លូវការ និងមិនផ្លូវការ
- តម្រូវឱ្យគរុសិស្ស គរុនិស្សិតបង្ហាញពីចំណេះដឹងនិងយកទៅអនុវត្ត ព្រមទាំងត្រិះរិះពិចារណា និងវិភាគស៊ីជម្រៅ
- គាំទ្រគរុនិស្សិតក្នុងការអភិវឌ្ឍ និងកែលម្អឥរិយាបថវិជ្ជាជីវៈ ជំនឿ អកប្បកិរិយា និងការប្រតិបត្តិ។

ដូច្នេះរាល់សកម្មភាពវាយតម្លៃត្រូវបន្សុីជាមួយជំហាននៃការសិក្សា ដូចមានចែងក្នុងឯកសារណែនាំសមត្ថភាពអប់រំគរុនិស្សិត។

## ១២.២ ប្រព័ន្ធពិន្ទុ និងនិទ្ទេស

នៅក្នុងកម្មវិធីអប់រំគ្រូបង្រៀន គ្រប់មុខវិជ្ជាបង្រៀន និងសកម្មភាពនានា ដូចជាសមាសភាគកម្មសិក្សាគរុកោសល្យ របាយការណ៍គម្រោងស្រាវជ្រាវប្រតិបត្តិ ឬនិក្ខេបបទ/សារណា នឹងត្រូវដាក់ពិន្ទុដោយប្រើប្រាស់ប្រព័ន្ធដូចខាងក្រោម៖

*តារាងទី 14៖ ប្រព័ន្ធពិន្ទុ និងនិទ្ទេស*

| ពិន្ទុ ជាភាគរយ% | និទ្ទេសជាអក្សរ | ពិន្ទុនិទ្ទេស | និទ្ទេស |
|---|---|---|---|
| ៨៥%-១០០% | A | ៤.០០ | ល្អប្រសើរ |
| ៨០%-៨៤% | B+ | ៣.៥០ | ល្អណាស់ |
| ៧០%-៧៩% | B | ៣.០០ | ល្អ |
| ៦៥%-៦៩% | C+ | ២.៥០ | ល្អបង្គួរ |
| ៥០%-៦៤% | C | ២.០០ | មធ្យម |
| <៥០% | D | ១.៥០ | ធ្លាក់ |

នៅក្នុងកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ ការវាយតម្លៃចុងក្រោយផ្អែកលើមធ្យមភាគនៃពិន្ទុនិទ្ទេស (Grade Point Average-GPA)។

រូបមន្តគណនា GPA គឺមានដូចខាងក្រោម៖

*GPA ស្មើនឹងផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (P) និង ចំនួនក្រេឌីតនៃមុខវិជ្ជានីមួយៗ (C) ចែកនឹងផលបូកសរុបនៃចំនួនក្រេឌីតនៃមុខវិជ្ជានីមួយៗ (C)។*

$$GPA = \frac{\sum(P \times C)}{\sum C}$$

គ្រប់កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ មធ្យមភាគនៃពិន្ទុនិទ្ទេសជាប់គឺចាប់ពី ២.០០ ឡើងទៅ។

## ១២.៣ ការវាយតម្លៃមុខវិជ្ជាបង្រៀន

កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវវាយតម្លៃពីវឌ្ឍនភាព និងសមិទ្ធផលសម្រេចបានរបស់គរុនិស្សិតទៅលើមុខវិជ្ជាបង្រៀនដោយប្រើវិធីសាស្ត្រវាយតម្លៃតាមដំណាក់កាល និងការវាយតម្លៃបញ្ចប់។

ការវាយតម្លៃលើមុខវិជ្ជាបង្រៀនគឺរួមមានទម្រង់ផ្សេងៗជាច្រើនដូចជាវត្តមាន ការចូលរួមសកម្មភាពសិក្សា កិច្ចការសំណេរនិងការធ្វើបទបង្ហាញ តេស្តត្រួតពិនិត្យ និងការប្រឡងបញ្ចប់មុខវិជ្ជា។

ការវាយតម្លៃមុខវិជ្ជាបង្រៀនគឺផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១. វត្តមាន ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃអំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

### ១២.៣.១ វត្តមាន

វត្តមានគឺត្រូវបានវាយតម្លៃលើកម្រិតវត្តមានរបស់គរុនិស្សិតដែលចូលរួមស្តាប់បទឧទ្ទេស ការបង្ហាត់បង្ហាញ និងព្រឹត្តិការណ៍ដទៃទៀតដែលត្រូវបានកំណត់ឱ្យសិក្សាក្នុងមុខវិជ្ជាសិក្សា។

គរុនិស្សិតដែលបានចូលរៀនមុខវិជ្ជាបង្រៀននីមួយៗ ចាំបាច់ត្រូវមានវត្តមានយ៉ាងតិចបំផុត ៨០% ដើម្បីអាចចូលរួមប្រឡងបញ្ចប់មុខវិជ្ជាសិក្សា។ ប៉ុន្តែមានករណីលើកលែងចំពោះបុគ្គលមួយចំនួនដោយសារហេតុផលផ្នែកវេជ្ជសាស្ត្រ ហេតុផលផ្ទាល់ខ្លួន ឬដោយសារកាលៈទេសៈសមស្របដទៃទៀតអាស្រ័យទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

### ១២.៣.២ ការចូលរួមសកម្មភាពសិក្សា

ការចូលរួមក្នុងមុខវិជ្ជាសិក្សានឹងត្រូវបានវាយតម្លៃផ្អែកលើភាពញឹកញាប់ និងគុណភាពនៃសកម្មភាពចូលរួមរបស់គរុសិស្ស គរុនិស្សិតនៅក្នុងអំឡុងពេលសិក្សា។ ការចូលរួមក្នុងមុខវិជ្ជាសិក្សាគឺផ្តោតទៅលើជាតុផ្សេងៗដូចជាកម្រិតនៃការចូលរួមនៅក្នុងសកម្មភាពដែលបានកំណត់ ការផ្លាស់ប្តូរបទពិសោធន៍ជាមួយគ្រូឧទ្ទេស និងមិត្តរួមក្រុម ក្នុងការចែករំលែកគំនិត ធនធាន និងការផ្តល់មតិយោបល់និងព័ត៌មានត្រឡប់។

ការចូលរួមសកម្មភាពសិក្សាត្រូវបានវាយតម្លៃផ្អែកលើ៖

- កម្រិតនៃការចូលរួមរបស់ គរុនិស្សិត និងការរួមចំណែកក្នុងពេលឧទ្ទេស និងការបង្ហាត់បង្ហាញ
- កម្រិតនៃការចូលរួមរបស់គរុនិស្សិតនៅក្នុងសកម្មភាពពិភាក្សាក្រុម
- កម្រិតនៃការចូលរួមរបស់គរុនិស្សិតនៅក្នុងសកម្មភាពកិច្ចសហការរវាងមិត្តរួមថ្នាក់

### ១២.៣.៣ ការវាយតម្លៃអំឡុងពេលសិក្សា

ការវាយតម្លៃអំឡុងពេលសិក្សាគឺផ្អែកលើគុណភាពនៃកិច្ចការ ឬពិន្ទុដែលបានទទួលតាមរយៈការវាយតម្លៃតាមដំណាក់ផ្លូវការ តាមកាលវិភាគដែលបានកំណត់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀនក្នុងអំឡុងពេលសិក្សា។ កិច្ចការ វាយតម្លៃលើមុខវិជ្ជាសិក្សាជាផ្លូវការអាចរួមមាន៖

- កិច្ចការសំណេរ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ការធ្វើបទបង្ហាញ
- គម្រោងស្រាវជ្រាវប្រតិបត្តិ
- ការធ្វើតេស្តពាក់កណ្តាលឆមាស

ការរៀបចំកិច្ចការវាយតម្លៃគួរតែបន្សុីគ្នាជាមួយកិច្ចការវាយតម្លៃស្វ័យឆ្លុះបញ្ចាំង ដែលត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំឬក្រឹតការ ដើម្បីត្រៀមខ្លួនគរុនិស្សិតសម្រាប់អាជីពវិជ្ជាជីវៈដោយផ្អែកលើការសិក្សាពេញមួយជីវិត។

គរុនិស្សិតដែលបានចូលរៀនលើមុខវិជ្ជាបង្រៀននីមួយៗ ចាំបាច់ត្រូវបំពេញ និង/ឬ ប្រគល់កិច្ចការវាយតម្លៃទាំងអស់ដើម្បីអាចចូលរួមប្រឡងបញ្ចប់មុខវិជ្ជាសិក្សា។ប៉ុន្តែមានករណីលើកលែងចំពោះបុគ្គលមួយចំនួនដោយសារហេតុផលផ្នែកវេជ្ជសាស្ត្រ ហេតុផលផ្ទាល់ខ្លួន ឬដោយសារកាលៈទេសៈសមស្របដទៃទៀត អាស្រ័យទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

### ១២.៣.៤ ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា

ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សាគឺជាការវាយតម្លៃបញ្ចប់នៃមុខវិជ្ជាបង្រៀនទាំងអស់។ ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សានឹងត្រូវធ្វើឡើងនៅសប្តាហ៍ប្រឡងនៃឆមាសឬឆ្នាំសិក្សានីមួយៗដែលមុខវិជ្ជាសិក្សាត្រូវបានបង្រៀន។

ការប្រឡងអាចជា៖

- កិច្ចការសំណេរ
- កិច្ចការសំណួរចម្លើយខ្លីៗ
- កិច្ចការសំណួរចម្លើយពហុជ្រើសរើស
- កិច្ចការស្រាវជ្រាវមានរយៈពេលកំណត់
- និងការធ្វើបទបង្ហាញមានរយៈពេលកំណត់

គរុនិស្សិតដែលបានចូលរៀនមុខវិជ្ជាបង្រៀននីមួយៗ ចាំបាច់ត្រូវប្រឡងបញ្ចប់មុខវិជ្ជាសិក្សាដើម្បីបានទទួលពិន្ទុបញ្ចប់។ ប្រសិនបើគរុនិស្សិតប្រឡងធ្លាក់ក្នុងមុខវិជ្ជាបង្រៀនណាមួយ ពួកគេអាចប្រឡងឡើងវិញបានតែមួយលើកប៉ុណ្ណោះ។

## ១២.៤ ការវាយតម្លៃកម្មសិក្សាគរុកោសល្យ

គោលបំណងរបស់កម្មសិក្សាគរុកោសល្យគឺដើម្បីឱ្យគរុនិស្សិតយល់ច្បាស់ពីការរំពឹងទុក និងតម្រូវការនៃការបង្រៀនក្នុងថ្នាក់រៀន រួមបញ្ចូលជាមួយទិដ្ឋភាពដទៃទៀតទាំងអស់នៃជីវិតជាគ្រូបង្រៀន។ ហេតុដូចនេះឧបករណ៍ និងយន្តការដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃក្នុងពេលបំពេញកម្មសិក្សាគរុកោសល្យគួរបន្សុីជាមួយឧបករណ៍ និងយន្តការទាំងឡាយដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃគ្រូបង្រៀនអាជីព។

គ្រប់កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវធ្វើការវាយតម្លៃពីវឌ្ឍនភាព និងសមិទ្ធផលរបស់គរុនិស្សិតដោយផ្អែកទៅលើសមាសភាគកម្មសិក្សាគរុកោសល្យដែលបានទទួលស្គាល់ តាមរយៈវិធីសាស្ត្រវាយតម្លៃតាមដំណាក់ និងវាយតម្លៃបញ្ចប់។

ការវាយតម្លៃកម្មសិក្សាគរុកោសល្យរួមមាន វត្តមាន សកម្មភាពចូលរួមធ្វើកិច្ចតែងការបង្រៀន ការបង្រៀនក្នុងថ្នាក់រៀន និងសម្មភាពសាលារៀនដទៃទៀត ព្រមទាំងការរក្សាទុកផលបត្រកម្មសិក្សាគរុកោសល្យផ្អែកលើផែនការសិក្សាវិជ្ជាជីវៈ។

សមាសភាគកម្មសិក្សាគរុកោសល្យនីមួយៗនឹងត្រូវបានវាយតម្លៃដោយគ្រឹះស្ថានអប់រំគ្រូបង្រៀនសហការជាមួយសាលារៀនដែលគរុនិស្សិតចុះកម្មសិក្សាគរុកោសល្យ។

កម្មសិក្សាគរុកោសល្យត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១. វត្តមានអំឡុងពេលកម្មសិក្សាគរុកោសល្យ ១០%

២. សកម្មភាពចូលរួមក្នុងកម្មសិក្សាគរុកោសល្យ ២០%

៣. ការវាយតម្លៃអំឡុងពេលបំពេញកម្មសិក្សាគរុកោសល្យ ៣០%

៤. ផលបត្រកម្មសិក្សាគរុកោសល្យ ៤០%

### ១២.៤.១ វត្តមានអំឡុងពេលកម្មសិក្សាគរុកោសល្យ

វត្តមានក្នុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវវាយតម្លៃផ្អែកលើវត្តមានរបស់គរុនិស្សិតចូលរួម ការប្រឹក្សាគរុកោសល្យ ការសង្កេតថ្នាក់រៀន រយៈពេលនៃការបង្រៀនតាមកាលវិភាគដែលបានកំណត់ ការប្រជុំចាំបាច់ និងព្រឹត្តិការណ៍នានានៅសាលារៀន។

គរុនិស្សិតត្រូវមានវត្តមានយ៉ាងតិច ៨០% សម្រាប់កម្មសិក្សាគរុកោសល្យប្រចាំឆ្នាំនីមួយៗ ដើម្បីអាចចូលរួមប្រឡងបញ្ចប់កម្មវិធីអប់រំ។ ប៉ុន្តែមានករណីលើកលែងចំពោះបុគ្គលមួយចំនួនដោយសារហេតុផលផ្នែកវេជ្ជសាស្ត្រ ហេតុផលផ្ទាល់ខ្លួន ឬដោយសារកាលៈទេសៈសមស្របដទៃទៀត អាស្រ័យទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

### ១២.៤.២ សកម្មភាពចូលរួម អំឡុងពេលកម្មសិក្សាគរុកោសល្យ

សកម្មភាពចូលរួមអំឡុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវវាយតម្លៃផ្អែកលើការចូលរួម និងគុណភាពនៃការចូលរួមរបស់គរុនិស្សិតនៅក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗ។

សកម្មភាពចូលរួមក្នុងកម្មសិក្សាគរុកោសល្យរួមមាន កម្រិតនៃការចូលរួមអនុវត្តសកម្មភាពតាមសាលារៀនដែលបានកំណត់ ការផ្លាស់ប្តូរបទពិសោធន៍ជាមួយគ្រូបង្រៀននៅសាលារៀននិងមិត្តរួមក្រុម ការចូលរួមចំណែកក្នុងវគ្គវាយតម្លៃលទ្ធផលកម្មសិក្សាគរុកោសល្យ ការចែករំលែកគំនិតឬធនធាន និងការផ្តល់មតិយោបល់និងព័ត៌មានត្រឡប់ទៅកាន់គ្រូបង្រៀននៅសាលារៀន និងមិត្តរួមក្រុម។

ការវាយតម្លៃសកម្មភាពចូលរួមកម្មសិក្សាគរុកោសល្យផ្តោតលើកម្រិតចូលរួមរបស់គរុនិស្សិត៖

- អំឡុងពេល និងក្រោយពេលសង្កេតការបង្រៀន
- នៅក្នុងការប្រឹក្សាគរុកោសល្យ ឬសកម្មភាពពិភាក្សាក្រុម
- នៅក្នុងសកម្មភាពសហការរវាងមិត្តរួមក្រុម
- គរុនិស្សិត នៅក្នុងសាលារៀនឬសហគមន៍

### ១២.៤.៣ ការវាយតម្លៃអំឡុងពេលកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃអំឡុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវផ្អែកលើ គុណភាពកិច្ចការឬពិន្ទុដែលទទួលបានពីការបំពេញកិច្ចការក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យ ដែលជាផ្នែកមួយនៃការវាយតម្លៃកិច្ចការតាមដំណាក់ក្នុងឆ្នាំនីមួយៗ។

ការវាយតម្លៃអំឡុងពេលបំពេញកម្មសិក្សាគរុកោសល្យរួមមាន៖

- ការវាយតម្លៃលើកិច្ចតែងការបង្រៀន ផែនការសកម្មភាព ឬធនធានឯកសារដទៃទៀត

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ការវាយតម្លៃលើការអនុវត្តការបង្រៀន ដែលមានការសង្កេត និងវាយតម្លៃ
- ការវាយតម្លៃផ្អែកលើកម្រិតនៃការអភិវឌ្ឍវិជ្ជាជីវៈនៅអំឡុងពេលកម្មសិក្សាគរុកោសល្យ
- ការវាយតម្លៃផ្អែកទៅលើការវាយតម្លៃវិជ្ជាជីវៈជាប្រចាំ ដោយនាយកសាលា

### ១២.៤.៤ ផលបត្រកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃបញ្ចប់នៃសមាសភាគកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗផ្អែកលើ ការប្រគល់ផលបត្រកម្មសិក្សាគរុកោសល្យ។

គរុនិស្សិតត្រូវរក្សាផលបត្ររបស់ខ្លួនក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗ។ ផលបត្រកម្មសិក្សាគរុកោសល្យ រួមមានភស្តុតាងនៃសកម្មភាពដែលបានអនុវត្ត កិច្ចតែងការបង្រៀន និងការបង្រៀនរួមទាំងការឆ្លុះបញ្ចាំងពីចំណុចខ្លាំង ចំណុចខ្វះខាត និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

មាតិកាផលបត្រកម្មសិក្សាគរុកោសល្យអាចរួមមាន៖

- កំណត់ហេតុការបង្រៀនប្រចាំថ្ងៃដែលឆ្លុះបញ្ចាំងពីសកម្មភាពដែលបានអនុវត្ត និងមេរៀនទទួលបាន
- កំណត់ត្រាពីមេរៀនដែលបានសង្កេត
- កិច្ចតែងការបង្រៀន ផែនការសកម្មភាព និងធនធានដទៃទៀត
- ខ្លឹមសារសង្ខេបនៃការប្រឹក្សាគរុកោសល្យ សកម្មភាពជាមួយមិត្តរួមក្រុម
- ឯកសារថតចម្លងការវាយតម្លៃពីគ្រូណែនាំ និងការសង្កេតការបង្រៀនដែលបានវាយតម្លៃ
- កំណត់ត្រាស្វ័យឆ្លុះបញ្ចាំងផ្ដោតលើចំណុចខ្លាំង ចំណុចខ្វះខាត និងចំណុចដែលត្រូវកែលម្អ និងវិធីក្នុងការធ្វើការកែលម្អ
- ការសង្កេតលើទិដ្ឋភាពដទៃទៀតនៃជីវិតពិតក្នុងសាលារៀនរួមមាន ការគ្រប់គ្រងនិងរដ្ឋបាល និងការចូលរួមរបស់សហគមន៍ ទំនាក់ទំនងរវាងឪពុកម្ដាយជាមួយគ្រូបង្រៀន។ល។

ទម្រង់ផលបត្រកម្មសិក្សាគរុកោសល្យ គឺត្រូវផ្អែកលើផែនការសិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនម្នាក់ៗដែលតម្រូវដោយសៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ១២.៥ ការវាយតម្លៃសមាសភាគការស្រាវជ្រាវ

កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវវាយតម្លៃលើវឌ្ឍនភាព និងសមិទ្ធផលនៃការស្រាវជ្រាវរបស់គរុនិស្សិតតាមរយៈការវាយតម្លៃតាមដំណាក់ និងការវាយតម្លៃបញ្ចប់។

សមាសភាគនៃការស្រាវជ្រាវរួមមាន មុខវិជ្ជាបង្រៀន និងគម្រោងស្រាវជ្រាវប្រតិបត្តិ។

គរុនិស្សិតត្រូវបំពេញ និងប្រគល់របាយការណ៍ស្រាវជ្រាវប្រតិបត្តិដើម្បីអាចចូលរួមប្រឡងបញ្ចប់។ ប៉ុន្តែមានករណីលើកលែងចំពោះបុគ្គលមួយចំនួនដោយសារហេតុផលផ្នែកវេជ្ជសាស្ត្រ ហេតុផលផ្ទាល់ខ្លួន ឬដោយសារកាលៈទេសៈសមស្របដទៃទៀត អាស្រ័យទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

### ១២.៥.១ ការវាយតម្លៃលើមុខវិជ្ជាបង្រៀននៃការស្រាវជ្រាវ

មុខវិជ្ជាបង្រៀននៅក្នុងសមាសភាគការស្រាវជ្រាវនឹងត្រូវបានវាយតម្លៃផ្អែកលើរបៀប និងលក្ខណៈវិនិច្ឆ័យដូចគ្នានឹងមុខវិជ្ជាបង្រៀនស្តង់ដា (សូមមើលខាងលើ)។

ការវាយតម្លៃមុខវិជ្ជាដែលបានបង្រៀនគឺផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១. វត្តមាន ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%
៣. ការវាយតម្លៃ អំឡុងពេលសិក្សា ៣០%
៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

### ១២.៥.២ ការវាយតម្លៃលើគម្រោងស្រាវជ្រាវប្រតិបត្តិ

គរុនិស្សិតទាំងអស់ត្រូវរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិដែលមានការទទួលស្គាល់ទាក់ទងនឹងការអនុវត្តការបង្រៀន សមស្របនឹងបរិបទសាលារៀនដែលពួកគេចុះកម្មសិក្សាគរុកោសល្យ។

គម្រោងស្រាវជ្រាវរបស់គរុសិស្ស គរុនិស្សិតត្រូវត្រួតពិនិត្យដោយគ្រូឧទ្ទេសនៅគ្រឹះស្ថានអប់រំគ្រូបង្រៀនដែលជាគ្រូឧទ្ទេសដឹកនាំការស្រាវជ្រាវ។ គ្រូឧទ្ទេសដឹកនាំការស្រាវជ្រាវត្រូវផ្តល់ព័ត៌មានត្រឡប់ មតិយោបល់ជាលាយលក្ខណ៍អក្សរ និងការណែនាំទៀងទាត់ដល់គរុនិស្សិតដើម្បីធានាថាពួកគេធ្វើការស្រាវជ្រាវបានត្រឹមត្រូវ និងសរសេររបាយការណ៍ស្រាវជ្រាវប្រកបដោយគុណភាព។ គរុនិស្សិតនឹងត្រូវទទួលបានការប្រឹក្សាគរុកោសល្យពីគ្រូឧទ្ទេសដែលនឹងគាំទ្រការអនុវត្តការស្រាវជ្រាវរបស់ពួកគេ។

ការវាយតម្លៃគម្រោងស្រាវជ្រាវប្រតិបត្តិនឹងផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- សំណើស្រាវជ្រាវ ១០%
- ការវាយតម្លៃពីវឌ្ឍនភាពនៃការស្រាវជ្រាវ (ជួបប្រជុំជាមួយគ្រូដឹកនាំយ៉ាងតិចចំនួន ៤ដង) ២០%
- ការប្រគល់របាយការណ៍ និងការការពារការស្រាវជ្រាវបញ្ចប់ ៧០%

បន្ទាប់ពីបានពិភាក្សាលើកដំបូងជាមួយគ្រូឧទ្ទេសដឹកនាំ គរុនិស្សិតត្រូវដាក់សេចក្តីព្រាងដំបូងនៃសំណើស្រាវជ្រាវរបស់ខ្លួនដើម្បីទទួលបានការត្រួតពិនិត្យ។ សំណើស្រាវជ្រាវរួមមាន៖

- ប្រធានបទស្រាវជ្រាវ
- គម្រោងស្រាវជ្រាវ
- ក្របខណ្ឌពេលវេលានៃការស្រាវជ្រាវ

ក្រោយពីទទួលបានមតិយោបល់កែលម្អ គរុនិស្សិតត្រូវប្រគល់សេចក្តីព្រាងចុងក្រោយនៃសំណើស្រាវជ្រាវ។ គរុនិស្សិតត្រូវប្រគល់របាយការណ៍ស្រាវជ្រាវចុងក្រោយ ក្រោយពីទទួលបានមតិយោបល់កែលម្អក្នុងកិច្ចប្រជុំវាយតម្លៃចុងក្រោយ។

គរុនិស្សិតត្រូវបញ្ចប់ និងប្រគល់របាយការណ៍ស្រាវជ្រាវមុននឹងអាចចូលប្រឡងបញ្ចប់ការសិក្សាបាន។ ករណីមិនបានបំពេញគ្រប់លក្ខខណ្ឌក្នុងការស្រាវជ្រាវទេ គរុនិស្សិតមិនអាចបញ្ចប់ការសិក្សាបានទេ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១៣. បញ្ជីគន្ថនិទ្ទេស


- JICA (2018) Analysis on the Credit System of PRESET and CPD Programmes in Cambodia. Phnom Penh: JICA;
- JICA (2019) Teacher Education Subsector Analysis Report: For the strategic upgrade of basic teacher qualifications to the degree level. Phnom Penh: JICA;
- Ministry of Education, Youth and Sport, Teacher Training Department (2005) Pre-service Training Curriculum for Lower Secondary School Teachers (Curriculum of Regional Teacher Training Centers);
- Ministry of Education, Youth and Sport, Teacher Training Department (2006) Curriculum for Teacher Training: Curriculum of Teacher Training Basic Levels Taught at Primary School '12+2';
- Ministry of Education, Youth and Sport (2010/2016) *TPS*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport, Teacher Training Department (2011). *Curriculum for Preschool Teacher Training*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport. (2014). *Education Strategic Plan 2014-2018*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2016) *Preschool curriculum*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2016) *Primary curriculum*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2016) *Lower secondary curriculum*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport. (2016a). *Teacher policy action plan*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport. (2016b). Prakas No. 1003 on equivalency programme for upgrading teacher qualification. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2016c) *Curriculum Framework of General & Technical Education K12*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport, Teacher Training Department (2017). *Curriculum time sheet for primary-level education instructors 12+2*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport, Teacher Training Department (2017). Pre-service Training Curriculum for Lower Secondary School Teachers (Curriculum of Regional Teacher Training Centers). Phnom Penh: MoEYS;
- Ministry of Education, Youth and Sport, Teacher Training Department (2017) *Policy on Continuous Professional Development for Education Staff*. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2019a) Strengthening Teacher Education Programs in Cambodia: Curriculum Framework of Bachelor of Education, Provincial Teacher Training Center Teacher Educator Upgrading Program. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2019b) Continuous Professional Development Framework for Teachers and School Directors. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2021) Framework Bachelor of Arts (Education)

Teacher Education College (TEC). Phnom Penh: MoEYS/TEC;

- Ministry of Education, Youth and Sport (2021a) System for Continuous Professional Development Credit Acquisition. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2021b) CPD Handbook: a guide to continuous professional development for teachers, school directors and education specialists in Cambodia. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2021c) Mid-Term Plan for Teacher Qualification Upgrade 2021-2025: Accelerating the upgrade of basic teacher qualifications to degree level. Phnom Penh: MoEYS;
- Ministry of Education, Youth and Sport (2023) *Guideline on Student Teacher Education Competencies [Draft].* Phnom Penh: Educational Research and Library Publishing;
- Ministry of Education Youth and Sports (2022) Mid-Term Review Report of the ESP 2019-2023 and projection to 2025. Phnom Penh: MoEYS;
- Royal Kingdom of Cambodia (2012) *Cambodia Qualifications Framework*. Phnom Penh: MoEYS.

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## សទ្ទានុក្រម

| ពាក្យបច្ចេកទេស | និយមន័យ |
|---|---|
| ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស | ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេសសំដៅលើការសិក្សាដែលផ្តល់ការណែនាំឱ្យគរុនិស្សិតនូវខ្លឹមសារ បញ្ញត្តិ និងគោលការណ៍ជាមូលដ្ឋានគ្រឹះនៃមុខវិជ្ជា ដូចមានចែងក្នុងកម្មវិធីសិក្សាថ្នាក់មូលដ្ឋានរបស់ប្រទេសកម្ពុជា សម្រាប់កម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ "ចំណេះដឹងលើមុខវិជ្ជា/មុខវិជ្ជាឯកទេស" គឺមានន័យស្មើនឹងពាក្យ "ចំណេះដឹងមូលដ្ឋាន" ដូចដែលបានប្រើនៅក្នុងកម្មវិធីអប់រំរបស់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និង សាលាគរុកោសល្យនិងវិក្រឹតការ។ បច្ចុប្បន្ន កម្មវិធីអប់រំវិទ្យាស្ថានគរុកោសល្យប្រើប្រាស់ "ចំណេះដឹងលើមុខវិជ្ជា" សម្រាប់កម្មវិធីអប់រំគ្រូបង្រៀនកម្រិតបឋមសិក្សា និង "ចំណេះដឹងលើមុខវិជ្ជាឯកទេស" សម្រាប់កម្មវិធីអប់រំគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ។ កម្មវិធីអប់រំរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគប្រើ "ចំណេះដឹងលើមុខវិជ្ជាឯកទេស"។ |
| បណ្តុំមុខវិជ្ជាសិក្សា | បណ្តុំមុខវិជ្ជាសិក្សាសំដៅលើ ប្រភេទ មុខវិជ្ជានីមួយៗ និងខ្លឹមសារសំខាន់ៗនៃមុខវិជ្ជាទាំងនោះ។ ខ្លឹមសារនៃមុខវិជ្ជាសិក្សា ចំណេះដឹងគរុកោសល្យ ចំណេះដឹងតាមមុខវិជ្ជា ចំណេះដឹងវិជ្ជាជីវៈ ជំនាញប្រតិបត្តិ និងការស្រាវជ្រាវ។ |
| ក្របខណ្ឌគុណសម្បទា | ក្របខណ្ឌគុណសម្បទាគឺជាឧបករណ៍ដើម្បីបង្ហាញកម្រងគុណសម្បទាវិជ្ជាជីវៈដែលត្រូវបានរៀបចំឡើងសម្រាប់គ្រូបង្រៀន។ |
| ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺជាសកម្មភាពនៃការសិក្សាដែលបុគ្គលិកប្រកបដោយវិជ្ជាជីវៈចូលរួមសិក្សាដើម្បីអភិវឌ្ឍ និងពង្រឹងសមត្ថភាពរបស់ខ្លួនដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងជំនាញបុគ្គល និងភាពស្ទាត់ជំនាញនៅក្នុងអាជីពជាបន្តរបស់បុគ្គល។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមមានវិធីសាស្ត្រនៃការរៀន ទាំងក្នុងនិងក្រៅប្រព័ន្ធដូចជា ចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទ និងព្រឹត្តិការណ៍អប់រំ កម្មវិធីអប់រំពីចម្ងាយ ឬកម្មវិធីស្វ័យសិក្សា ឧត្តមានុវត្តន៍ និងការផ្លាស់ប្តូរបទពិសោធន៍ជាដើម។ |
| មុខវិជ្ជាសិក្សាស្នូល | មុខវិជ្ជាសិក្សាស្នូល(មុខវិជ្ជារួមនៃឯកទេស)សំដៅលើមុខវិជ្ជាទាំងឡាយណាដែលតម្រូវឱ្យសិក្សាក្នុងកម្មវិធីអប់រំគ្រូបង្រៀនគ្រប់កម្រិត រួមមាន ក) ជាបុរេលក្ខខណ្ឌសម្រាប់គ្រប់គ្រូបង្រៀនមានគុណវុឌ្ឍិទាំងអស់ ឬខ) ជាបុរេលក្ខខណ្ឌសម្រាប់ការបញ្ចប់ការសិក្សា។ |
| ក្រេឌីត | សំដៅលើឯកតាឬតម្លៃដែលយកជាខ្នាតសម្រាប់វាស់វែង និងពិពណ៌នាពីទំហំការងារ ឬបរិមាណនៃការសិក្សាដែលរំពឹងទុកសម្រាប់កម្រិតនីមួយៗ ឬសម្រាប់មុខវិជ្ជាសិក្សា ឯកតាសិក្សា ឬសមាសភាគដទៃទៀតនៃកម្មវិធីអប់រំ និងបណ្តុះបណ្តាល។ |

| | |
|---|---|
| ម៉ោងក្រេឌីត | សំដៅលើទំហំការងារតាមការប៉ាន់ប្រមាណដោយផ្អែកលើចំនួនម៉ោងសិក្សាដែលតម្រូវឱ្យទទួលបានក្រេឌីតក្នុងមួយមុខវិជ្ជាសិក្សានៃកម្មវិធីអប់រំដែលមានការទទួលស្គាល់។ |
| ក្របខណ្ឌកម្មវិធីសិក្សា | សំដៅលើឯកសារណែនាំដែលកំណត់គោលបំណង និងវត្ថុបំណងនៃកម្មវិធីសិក្សា បង្ហាញរចនាសម្ព័ន្ធកម្មវិធីសិក្សា ការបែងចែកក្រេឌីត និងម៉ោងសិក្សា សម្រាប់ការអនុវត្តសកម្មភាពផ្សេងៗ។ |
| កម្មវិធីសិក្សា | សំដៅលើឯកសារដែលផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងសកម្មភាពសិក្សា និងលទ្ធផលសិក្សារំពឹងទុកដើម្បីទទួលបានពិន្ទុសម្រាប់មុខវិជ្ជាសិក្សានីមួយៗ។ បំណិនសម្បទា គុណសម្បទា និងខ្លឹមសារចំណេះដឹងសម្រាប់មុខវិជ្ជានីមួយៗត្រូវបានរៀបចំតាមវិសាលភាព និងលំដាប់លំដោយនៃការសិក្សា។ កម្មវិធីសិក្សាខុសពីកម្មវិធីសិក្សាលម្អិត( សូមមើលនិយមន័យតំណភ្ជាប់ខាងក្រោម )។ |
| ការសិក្សាពីកម្មវិធីសិក្សា | សំដៅលើមុខវិជ្ជាសិក្សាដែលណែនាំឱ្យគរុនិស្សិតទទួលបានចំណេះដឹងគរុកោសល្យឯកទេស និងជំនាញជាក់លាក់ពាក់ព័ន្ធនឹងមុខវិជ្ជាបង្រៀននៅសាលារៀនស្របតាមតម្រូវការនៃកម្មវិធីអប់រំកម្រិតមូលដ្ឋាននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ពាក្យ “ការសិក្សាពីកម្មវិធីសិក្សា” សមមូលជាមួយពាក្យ “ចំណេះដឹង និងវិធីសាស្រ្តបង្រៀនថ្នាក់មត្តេយ្យសិក្សា” នៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១ ឬ “វិធីសាស្រ្តបង្រៀនតាមមុខវិជ្ជា” នៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា១២+២ តាមប្រព័ន្ធក្រេឌីតឆ្នាំ២០១៧។ |
| ការសិក្សាពីការអប់រំ | សំដៅលើបណ្តុំមុខវិជ្ជាទាំងឡាយណាដែលផ្តល់ការយល់ដឹងពីបញ្ញតិគន្លឹះ និងគោលការណ៍សំខាន់ៗនៃការអប់រំដែលចាំបាច់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការប្រតិបត្តិបែបឆ្លុះបញ្ចាំងនៅក្នុងសាលារៀននៅកម្ពុជា។ បណ្តុំមុខវិជ្ជាការសិក្សាពីការអប់រំ សមមូលជាមួយពាក្យ “បំណិនវិជ្ជាជីវៈ” ដែលប្រើប្រាស់នៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១។ |
| មុខវិជ្ជាសិក្សាជម្រើស | សំដៅលើបណ្តុំមុខវិជ្ជា ទាំងឡាយណាដែលជាការបំពេញបន្ថែម ឬជាការដាក់បន្ថែមទៅលើបណ្តុំមុខវិជ្ជាតម្រូវសម្រាប់បញ្ចប់ការសិក្សា។ មុខវិជ្ជាទាំងអស់នេះគរុនិស្សិតអាចជ្រើសរើសបានផ្អែកលើចំណង់ចំណូលចិត្តវិជ្ជាជីវៈ ឬចំណង់ចំណូលចិត្តបុគ្គល។ |
| សកម្មភាពក្រៅកម្មវិធីអប់រំ | សំដៅលើសកម្មភាពក្រៅកម្មវិធីអប់រំ ដែលជាតម្រូវការផ្ទាល់របស់គ្រឹះស្ថានអប់រំគ្រូបង្រៀននីមួយៗ។ សកម្មភាពនោះរួមមាន កិច្ចការ និងសកម្មភាពពាក់ព័ន្ធជាមួយនឹងការងារសង្គម ឬភាពជាពលរដ្ឋ សុខភាពផ្លូវកាយ និង/ឬ សុខុមាលភាពផ្លូវចិត្តរបស់គរុនិស្សិត។ |
| វិក្រឹតការ | សំដៅលើដំណើរការទាំងឡាយណាដែលមានគោលបំណងលើកកម្ពស់គុណវុឌ្ឍិ ឬអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន រួមមានចំណេះដឹងវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ ការ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រតិបត្តិវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈក្នុងអំឡុងពេលបំពេញការងារក្នុងអាជីពរួម បញ្ចូលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ចំណេះដឹងគរុកោសល្យ — សំដៅលើបណ្តុំមុខវិជ្ជាសិក្សាទាំងឡាយណាដែលផ្តល់ឱ្យគរុនិស្សិតនូវបញ្ញត្តិនិងគោលការណ៍គន្លឹះ ក្នុងការបង្រៀនសិស្ស រួមមានទ្រឹស្តី គោលវិធីបង្រៀន និងវិធីសាស្ត្របង្រៀន សម្រាប់ការបង្រៀនសិស្សនៅមត្តេយ្យសិក្សា បឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ។

កម្មសិក្សាគរុកោសល្យ — សំដៅលើសកម្មភាព និងសមាសភាគការសិក្សាដែលទទួលបានក្រេឌីត ដោយក្នុងនោះគរុនិស្សិតត្រូវបានផ្សារភ្ជាប់ទំនាក់ទំនងទៅនឹងសាលារៀនផ្ទាល់ដើម្បីឱ្យគរុនិស្សិតអាចសង្កេត អភិវឌ្ឍ និងអនុវត្តគុណសម្បទាក្នុងការបង្រៀននៅក្នុងបរិបទផ្សេងៗទៅតាមកម្រិតខុសៗគ្នា។ កម្មសិក្សាគរុកោសល្យរួមមានសកម្មភាពពាក់ព័ន្ធ ការរៀបចំកិច្ចតែងការបង្រៀន ការបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស ការគ្រប់គ្រងថ្នាក់រៀន រដ្ឋបាលសាលារៀន និងវិជ្ជាជីវៈបង្រៀន។

ការអប់រំគ្រូបង្រៀន — សំដៅលើកម្មវិធីអប់រំទាំងឡាយណាដែលត្រូវបានរៀបចំឡើងដើម្បីអប់រំអនាគតគ្រូបង្រៀនដែលមានគុណវុឌ្ឍិនិងមានការទទួលស្គាល់ជាផ្លូវការ ដើម្បីទៅបម្រើការនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន។

ការស្រាវជ្រាវ — សំដៅលើមុខវិជ្ជាសិក្សានិងសកម្មភាពទាំងឡាយណា ដែលជួយលើកកម្ពស់សមត្ថភាពគរុនិស្សិត ក្នុងការរៀបចំរចនាសម្ព័ន្ធស្រាវជ្រាវ ការប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យ។ ពាក្យស្រាវជ្រាវសមមូលជាមួយនឹងពាក្យ "ការស្រាវជ្រាវគរុកោសល្យ" ដែលប្រើនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឆ្នាំ២០១១ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា១២+២ តាមប្រព័ន្ធក្រេឌីតឆ្នាំ២០១៧ និងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ ១២+២ ឆ្នាំ២០១៩។

មុខវិជ្ជាសិក្សាកាតព្វកិច្ច — មុខវិជ្ជាសិក្សាកាតព្វកិច្ច (មុខវិជ្ជាស្នូលនៃឯកទេស)សំដៅលើមុខវិជ្ជាសិក្សាឬសកម្មភាពទាំងឡាយណា ដែលទទួលបានក្រេឌីត និងជាការតម្រូវ ឬកាតព្វកិច្ចដើម្បីទទួលបានគុណវុឌ្ឍិជាគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាជាដើម។ មុខវិជ្ជាទាំងនេះអាចមានដូចជា វិទ្យាសាស្ត្រ ភាសា សិល្បៈ។ល។

ចំណេះដឹងមុខវិជ្ជាឯកទេស — សំដៅលើបណ្តុំមុខវិជ្ជាសិក្សាទាំងឡាយណា ដែលផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពីបញ្ញត្តិ និងគោលការណ៍គ្រឹះនៃមុខវិជ្ជាសិក្សា។ មុខវិជ្ជាទាំងនេះនឹងជួយពង្រឹងភាពស្ទាត់ជំនាញរបស់គរុនិស្សិត លើខ្លឹមសារមុខវិជ្ជា និងជួយគាំទ្រគរុនិស្សិតក្នុងការត្រៀមខ្លួនបង្រៀននៅតាមសាលារៀន។

កម្មវិធីសិក្សាលម្អិត — សំដៅលើឯកសារទាំងឡាយណាដែលគូសបញ្ជាក់អំពីគោលបំណង ការជ្រើសរើស និងលំដាប់លំដោយនៃខ្លឹមសារមេរៀនសម្រាប់មុខវិជ្ជាសិក្សានីមួយៗ មេរៀន វិធីសាស្ត្របង្រៀន សម្ភារឧបទេស កិច្ចការ សកម្មភាពសិក្សា វត្ថុបំណងឬលទ្ធផលសិក្សារំពឹងទុក និងយន្តការវាយតម្លៃ។

| | |
|---|---|
| គុណសម្បទាគ្រូបង្រៀន | សំដៅលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីទទួលបានឋានៈជាគ្រូបង្រៀនដែលមានគុណវុឌ្ឍិ។ |
| ការឆ្លងភូមិសិក្សា | សំដៅលើយន្តការនានាដែលគ្រូបង្រៀនអាចឈានទៅក្នុងកម្មវិធីអប់រំបន្ថែម ផ្អែកលើគុណវុឌ្ឍិ ឬក្រេឌីតទទួលបានតាមរយៈការសិក្សាកន្លងមក ឬតាមរយៈសេវាបង្រៀន។ |
| ការដំឡើងគុណវុឌ្ឍិ | សំដៅលើយន្តការនានាដែលគ្រូបង្រៀនអាចអភិវឌ្ឍគុណវុឌ្ឍិវិជ្ជាជីវៈ ឋានៈវិជ្ជាជីវៈ វិជ្ជាសម្បទា ឬបំណិនសម្បទាដែលមានស្រាប់ តាមរយៈការសិក្សាបន្ថែមដែលមានការទទួលស្គាល់។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews